**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 09-Apr-2013, 15:38
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ ជាមួយឧបសម្ព័ន្ធចំនួនមួយ**
**សាធារណៈ និងឧបសម្ព័ន្ធចំនួនពីរសម្ងាត់**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អំពីឧបសម្ព័ន្ធទី ១២ និងទី ១៣ ដែលបានកែសម្រួលឡើងវិញ ក្នុងបញ្ជីឯកសារសម្រាប់សវនាការរបស់ខ្លួន អនុលោមតាមវិធាន៨០(៣)**
**(កំណត់ហេតុស្តាប់ចម្លើយសាក្សី និងពាក្យបណ្តឹង)**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
ខៀវ សំផន

ក្រុមមេធាវីការពារក្តី:
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSE
លោក Arthur VERCKEN
លោក Jacques VER

Elisabeth SIMONNEAU FORT

# I. សេចក្តីផ្តើម និងនិដ្ឋភាពទូទៅអំពីឧបសម្ព័ន្ធដែលបានកែសម្រួលឡើងវិញ

១- ជាការឆ្លើយតបទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីគោលការណ៍នៃការគ្រប់គ្រងលើភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រមទាំងសំណើរបស់អង្គជំនុំជម្រះ ដែលសុំឱ្យភាគីកាត់បន្ថយចំនួនកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលខ្លួនមានរិះរកដាក់នៅចំពោះមុខអង្គជំនុំជម្រះ[1] អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមដាក់ជូនឧបសម្ព័ន្ធទី១២ និងទី១៣ ដែលបានកែសម្រួលឡើងវិញ ពីបញ្ជីឯកសារដើមរបស់ខ្លួន អនុលោមតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង ដែលមាន៖ ក)កំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលបានដឹកនាំធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត (កសចស) អ្នកស្រាវជ្រាវពីខាងក្រៅ និងស្ថាប័នមិនមែន អ.វ.ត.ក (ឧបសម្ព័ន្ធទី១២) និង ខ)ពាក្យបណ្តឹងដែលសហព្រះរាជអាជ្ញាបានទទួល នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរក្នុងសំណុំរឿងនេះ (ឧបសម្ព័ន្ធទី១៣)។

២- ឧបសម្ព័ន្ធទី១២ ដែលបានកែសម្រួលឡើងវិញ មានកំណត់ហេតុចំនួន៨៧៤ ដែលរួមមាន៖ ក)កំណត់ហេតុចំនួន៨៥៧ ដែលបានដាក់បញ្ចូលពីដំបូងក្នុងឧបសម្ព័ន្ធទី១២ ខ)កំណត់ហេតុពីរបន្ថែមដែលបានទទួលយកដោយអង្គជំនុំជម្រះតាំងពីចាប់ផ្តើមសវនាការ[2] និង គ)កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន១៥ ដែលទទួលបានដោយ កសចស ក្នុងសំណុំរឿង ០០៣ និង០០៤ បន្ទាប់ពីការដាក់បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០(៣) និងដែលបានដាក់បញ្ចូលទៅក្នុងការបង្ហាញនាពេលថ្មីៗនេះដោយសហព្រះរាជអាជ្ញា[3]។ ឧបសម្ព័ន្ធទី១៣ ដែលបានកែសម្រួលឡើងវិញមាន៖ ពាក្យបណ្តឹងចំនួន១៦៦ ជារួម ឧបសម្ព័ន្ធទាំងពីរ ដែលបានកែសម្រួលឡើងវិញ មានឯកសារចំនួន**១០៤០** (ដែលជាការកាត់បន្ថយជាង៤៣% ពីឯកសារដើមដែលសរុបទាំងអស់មានចំនួន**១៨២៩**។ ឯកសារ

---

[1] **E223/2** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈ របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភស្តុតាងគាំទ្រ (ឯកសារ E223), ១៩ តុលា ២០១២, កថាខណ្ឌទី៩។ **E96/7** សេចក្តីសម្រេចលើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២ ទាក់ទងនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារដទៃទៀត នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ២០ មិថុនា ២០១២, កថាខណ្ឌទី៣៥(គ) (ពីនេះតទៅហៅថា "**E96/7** សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយសាក្សី")។

[2] **E190.1.405** និង **E190.1.406**។

[3] កំណត់ហេតុទាំងនេះងាយស្រួលកំណត់អត្តសញ្ញាណ ដោយសារលេខឯកសាររបស់វាចាប់ផ្តើមដោយ "**E127/5.1**" ។

ចំនួន១៧០ ក្នុងចំណោមឯកសារចំនួន១០៤០ គឺជាកំណត់ហេតុស្តាប់ចម្លើយសាក្សី និងបណ្តឹងរបស់សាក្សីដែលបានផ្តល់សក្ខីកម្មរួចហើយ និងដូចនេះគួរត្រូវទទួលយកដោយមិនចាំបាច់មានសំណើរបស់សហព្រះរាជអាជ្ញា។ កំណត់ហេតុស្តាប់ចម្លើយសាក្សី និងបណ្តឹងរបស់សាក្សីដាក់បញ្ចូលនៅក្នុងការដាក់សេចក្តីសន្និដ្ឋាននេះសម្រាប់ការបញ្ចប់ចុងក្រោយ (សូមមើលផ្នែក ក នៃឧបសម្ព័ន្ធទី១២ និង១៣ ដែលកែសម្រួលឡើងវិញ)។

៣- ការជ្រើសរើសឯកសារទាំងអស់នេះ គឺផ្អែកទៅលើវិសាលភាពនៃសំណុំរឿង ០០២/០១ ដូចដែលបានកំណត់ដោយសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ ២០១៣[4]។ ដោយហេតុថាសំអាងហេតុចំពោះសេចក្តីសម្រេចនេះមិនអាចរកបាននៅក្នុងពេលសរសេរនេះ សហព្រះរាជអាជ្ញាសូមរក្សាសិទ្ធិរបស់ខ្លួនក្នុងការកែសម្រួលបន្ថែមទៀតចំពោះឧបសម្ព័ន្ធ១២ និង ១៣ ប្រសិនបើចាំបាច់ នៅពេលចេញសំអាងហេតុជាលាយល័ក្ខណ៍អក្សរពេញលេញ។

៤- នៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី និងបណ្តឹងរបស់សាក្សីចំនួន១០៤០ នៅក្នុងឧបសម្ព័ន្ធកែសម្រួលឡើងវិញ សហព្រះរាជអាជ្ញាបានកំណត់ឃើញថាមានឯកសារចំនួន២២០ មានផ្ទុកនូវភ័ស្តុតាងសម្រាប់បញ្ជាក់អំពីអំពើ និងសកម្មភាពរបស់ជនជាប់ចោទ ដូចបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ (ពីនេះតទៅហៅថា"ភ័ស្តុតាងបញ្ជាក់ពីសកម្មភាព និងអំពើរបស់ជនជាប់ចោទ") **<u>ហើយ</u>**ដែលម្ចាស់ឯកសារទាំងនេះមិនបានមកបំភ្លឺនៅក្នុងពេលសរសេរ។ ដោយមានកត់សម្គាល់អំពីការសម្រេចរបស់អង្គជំនុំជម្រះ ស្តីពីភាពអាចទទួលយកបាននូវសម្ភារៈភ័ស្តុតាងដូច្នេះ សហព្រះរាជអាជ្ញាក៏បានផលិតច្បាប់ចម្លងនៃឯកសារទាំងនេះ ដែលខ្លឹមសាររួមមានភ័ស្តុតាងអំពីសកម្មភាព និងអំពើរបស់ជនជាប់ចោទត្រូវបានកំណត់សម្រាប់ការពិចារណា និងអាចដកចេញដោយតុលាការ (សូមយោងផ្នែក IV (ក)ខាងក្រោម) បើសិនជាសាក្សីទាំងនេះមិនបានមកបំភ្លឺនៅមុខពេលបិទសវនាការ។ បុគ្គលមួយចំនួននៃក្រុមទាំងនេះ ត្រូវបានជ្រើសរើសឲ្យមកផ្តល់សក្ខីកម្មដោយអង្គជំនុំជម្រះរួចហើយ។

៥- សហព្រះរាជអាជ្ញាសន្និដ្ឋានថា ឯកសារទាំង១០៤០ (រួមទាំងឯកសារភ្ជាប់ទាំងអស់ទៅជាមួយផង) ដែលមានឈ្មោះក្នុងបញ្ជីនៃឧបសម្ព័ន្ធទី១២ និងទី១៣ ដែលបានកែសម្រួលឡើងវិញ គួរត្រូវបានទទួល

[4] សេចក្តីព្រាងប្រតិចារឹកនៃសំណុំរឿង០០២, ២៩ មីនា ២០១៣, ទំព័រទី៥។

យកដោយហេតុថា ឯកសារទាំងនោះជាប់ពាក់ព័ន្ធនឹងបញ្ហាផ្សេងៗដែលមាននៅចំពោះមុខអង្គជំនុំជម្រះ និងជឿទុកចិត្តបាន។ ឯកសារទាំងនេះ គួរត្រូវបានទទួលយកដូចតទៅនេះ៖

ក. ទទួលយកទាំងស្រុងក្នុងករណី

i. ម្ចាស់កំណត់ហេតុនឹងបានផ្តល់សក្ខីកម្មក្នុងអំឡុងសវនាការ ឬក្នុងករណីដែលម្ចាស់កំណត់ហេតុនោះបានទទួលមរណភាព ឬមិនអាចរកបានឡើយ(មិននិយាយអំពីថាកំណត់ហេតុនោះ មាន ឬមិនមានភ័ស្តុតាងអំពីអំពើ និងសកម្មភាពរបស់ជនជាប់ចោទ) និង

ii. ម្ចាស់កំណត់ហេតុនឹងមិនបានមកផ្តល់សក្ខីកម្ម និងកំណត់ហេតុនោះមិនមានភ័ស្តុតាងបង្ហាញអំពីអំពើ និងសកម្មភាពរបស់ជនជាប់ចោទ។

ខ. ត្រូវបានទទួលយក ដោយមិនរាប់បញ្ចូលផ្នែកដែលបានបញ្ជាក់ (អំពើ និងសកម្មភាពរបស់ជនជាប់ចោទ) ក្នុងករណីដែលសាក្សីទាំងនោះអាចរកបាន ប៉ុន្តែមិនបានផ្តល់សក្ខីកម្មក្នុងពេលសវនាការ។

ឧបសម្ព័ន្ធ ក ក្នុងសេចក្តីសន្និដ្ឋាននេះ មានខ្លឹមសារទូទៅនៃឧបសម្ព័ន្ធទី១២ និង១៣ និងបង្ហាញអំពីថាតើប្រភេទទាំងនោះនៃកំណត់ហេតុស្តាប់ចម្លើយសាក្សី និងពាក្យបណ្តឹងអាចត្រូវបានកំណត់អត្តសញ្ញាណយ៉ាងដូចម្តេច។

៦- អង្គជំនុំជម្រះបានអនុម័តយកអភិក្រមខុសៗគ្នាចំពោះឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធទី១១ នៃបញ្ជីឯកសារដើមរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០(៣) តាមរយៈការទទួលយកឯកសារមួយចំនួនដែលបានចុះបញ្ជីក្នុងឧបសម្ព័ន្ធនោះ ហើយក៏ពុំដាក់លក្ខខណ្ឌតម្រូវឲ្យច្រានចោលផ្នែកដែលជាប់ពាក់ព័ន្ធនឹងសកម្មភាព និងអំពើរបស់ជនជាប់ចោទដែរ (ផ្នែក III(គ) ខាងក្រោម)។ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះទទួលយកឯកសារដែលនៅសល់ទាំងអស់ក្នុងឧបសម្ព័ន្ធទី១១ នៅពេលនេះ។

## II. ប្រវត្តិនីតិវិធី

៧- នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួនដែលបានស្នើសម្រាប់ធ្វើសវនាការនៅពេលជំនុំជម្រះ[5]។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា មានបុគ្គលខ្លះមិនត្រូវបានដាក់បញ្ចូលក្នុងបញ្ជីនេះទេ ដោយសំអាងថា កំណត់ហេតុជាលាយល័ក្ខណ៍អក្សររបស់ពួកគាត់ នឹងត្រូវបញ្ចូលជាភ័ស្តុតាង[6]។ សហព្រះរាជអាជ្ញាបានដាក់បញ្ជីឯកសាររបស់ខ្លួន អនុលោមតាមវិធាន៨០(៣) នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១[7]។ បញ្ជីនោះរួមមាន ប្រតិចារឹកនៃសំណុំរឿង ០០១ (ឧបសម្ព័ន្ធទី១១) កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត និងដោយបុគ្គល / អង្គការផ្សេងៗទៀត (ឧបសម្ព័ន្ធទី១២) និងពាក្យបណ្តឹងដែលទទួលបាននៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ (ឧបសម្ព័ន្ធទី១៣)។

៨- នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋាន អនុលោមតាមវិធាន៩២ នៃវិធានផ្ទៃក្នុង ទាក់ទងនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីជាលាយល័ក្ខណ៍អក្សរជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់[8]។ សហព្រះរាជអាជ្ញាបានធ្វើការសន្និដ្ឋាន *នៅក្នុងចំណោមការសន្និដ្ឋានផ្សេងៗទៀត* ថា ក)ជនជាប់ចោទមិនមានសិទ្ធិផ្តាច់មុខដើម្បីកោះហៅ និងសួរដេញដោលសាក្សីនៅពេលជំនុំជម្រះទេ ខ)អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ដោយពុំចាំបាច់កោះហៅសាក្សីទាំងអស់ឲ្យមកបំភ្លឺក្នុងសវនាការឡើយ និង គ)ក្នុងអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន អង្គជំនុំជម្រះគួរត្រូវបានណែនាំដោយសេចក្តីពិចារណាមួយចំនួន រួមមានគោលការណ៍អន្តរជាតិជាធរមាន (ដូចជា គោលការណ៍នានាដែលអនុវត្តចំពោះកំណត់ហេតុដែលមានភ័ស្តុតាងអំពីសកម្មភាព និងអំពើរបស់ជនជាប់ចោទ) ព្រមទាំង នីតិវិធីច្បាប់រដ្ឋប្បវេណីជាធរមាន នៅ អ.វ.ត.ក[9]។ ក្រុមមេធាវីការពារក្តីបានជំទាស់នឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញានេះ[10] ខណៈ

[5] **E9/4** បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០ នៃវិធានផ្ទៃក្នុង រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១, ទី២, ទី៣, ទី៣ក, ទី៤ និងទី៥, ២៨ មករា ២០១១។

[6] ឯកសារដដែលដូចខាងលើ, កថាខណ្ឌទី១០។

[7] **E9/31** បញ្ជីឈ្មោះឯកសារសម្រាប់សវនាការរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០(៣), ១៩ មេសា ២០១១។

[8] **E96** សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ១៥ មិថុនា ២០១១។

[9] ឯកសារដដែលដូចខាងលើ។

ដែលភាគីដើមបណ្តឹងរដ្ឋប្បវេណី គាំទ្រចំពោះសេចក្តីសន្និដ្ឋាននេះ[11]។ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១ សហព្រះរាជអាជ្ញា ក៏បានឆ្លើយតបទៅនឹងចម្លើយតបនោះ[12]។

៩- នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបំបែកសំណុំរឿង០០២ ទៅជាវគ្គនៃការជំនុំជម្រះ ដែលវគ្គទីមួយ (សំណុំរឿងលេខ០០២/១) ត្រូវបានដាក់បញ្ចូលការចោទប្រកាន់ខាងអង្គហេតុដែលជាប់ទាក់ទងនឹង៖ ក) ប្រវត្តិសាវតារ រចនាសម្ព័ន្ធសិទ្ធិអំណាច រចនាសម្ព័ន្ធឃោធា និងការប្រាស្រ័យទាក់ទងរបស់បក្សកុម្មុយនីស្តកម្ពុជា (បកក)/កម្ពុជាប្រជាធិបតេយ្យ តួនាទីរបស់ជនជាប់ចោទនៅក្នុង បកក/កម្ពុជាប្រជាធិបតេយ្យ និងគោលនយោបាយនានាដែលបានចោទប្រកាន់ថា ជាផ្នែកមួយនៃការចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួម ដូចបានរៀបរាប់ក្នុងដីកាដំណោះស្រាយ (រួមបញ្ចូលគ្នា - "ដំណាក់កាលដំបូង") និង ខ) ឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់ថាបានប្រព្រឹត្តជាផ្នែកមួយនៃព្រឹត្តិការណ៍នានាដូចបានរៀបរាប់ថាជាការជម្លៀសប្រជាជនក្នុងដំណាក់កាលទី១ និងទី២ (ដំណាក់កាលទីពីរ)[13]។ ដំណាក់កាលទីពីរនេះ ត្រូវបានពង្រីកជាបន្តបន្ទាប់ ដើម្បីបញ្ចូលការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធនឹងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ[14]។

---

[10] **E96/1** សារណាឆ្លើយតបទៅនឹងការសន្និដ្ឋានរបស់ កសព ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុជាលាយល័ក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី, ២១ កក្កដា ២០១១។ **E96/4** សេចក្តីសង្កេតតបទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី, ២២ កក្កដា ២០១១។

[11] **E96/5** ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ២២ កក្កដា ២០១១, កថាខណ្ឌទី៦។

[12] **E96/6** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបនានាទាក់ទងនឹងការទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ១០ សីហា ២០១១។

[13] **E163/5** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន, ៨ តុលា ២០១២។

[14] **E163/5** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន, ៨ តុលា ២០១២។

១០- នៅក្នុងខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះបានបើកសវនាការស្តីពីភាពអាចទទួលយកបាននៃឯកសារក្នុង **ឧបសម្ព័ន្ធ ១-៥** នៃបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០(៣)[15]។ ក្នុងខែមករា និងខែកុម្ភៈ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មនានាពាក់ព័ន្ធនឹងអាគតដ្ឋាននៃប្រភេទភ័ស្តុតាងដែលប្រមូលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)[16]។ ក្នុងខែមីនា ឆ្នាំ២០១២ អង្គជំនុំជម្រះបានបើកសវនាការស្តីពីភាពអាចទទួលយកបាននៃឯកសារនៅក្នុង **ឧបសម្ព័ន្ធ ៦-១១** និង **១៤-២០**[17]។ សវនាការស្តីពីការទទួលយកឯកសារនេះ ផ្តោតលើឯកសារដែលពាក់ព័ន្ធនឹងដំណាក់កាលទីមួយ ដែលជាការពិតគ្របដណ្តប់លើឯកសារភាគច្រើននៃឧបសម្ព័ន្ធដូចដែលបានជម្រាបជូនខាងលើនេះ[18]។

១១- នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចរបស់ខ្លួន ស្តីពីការទទួលយកឯកសារដំណាក់កាលដំបូង ដែលបានចុះបញ្ជីក្នុង **ឧបសម្ព័ន្ធ ១-៥** ដោយទទួលយកឯកសារទាំងអស់ លើកលែងតែ១២ឯកសារចេញ[19]។ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចដោយដាក់ចូលក្នុងសំណុំរឿងនូវឯកសារចំនួន៤៤៤ ក្នុងចំណោមឯកសារ "ថ្មី" ចំនួន៤៤៨ ដែលបំបែកចេញពីឧបសម្ព័ន្ធទាំងឡាយក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨០(៣) (ឯកសារដែលមិនមាននៅក្នុងសំណុំរឿង ក្នុងពេលដាក់បញ្ជីនោះ)[20]។

---

[15] **E1/27.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៦ មករា ២០១២។ **E1/28.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៧ មករា ២០១២។ **E1/29.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៨ មករា ២០១២។

[16] **E1/31.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ២៣ មករា ២០១២។ **E1/32.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ២៤ មករា ២០១២។ **E1/33. 1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី ២៥ មករា ២០១២។ **E1/37.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី ១ កុម្ភៈ ២០១២ ។ **E1/38.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ២ កុម្ភៈ ២០១២។ **E1/39.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៦ កុម្ភៈ ២០១២។

[17] **E1/46.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១២ មីនា ២០១២។ **E1/47.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៣ មីនា ២០១២។ **E1/48.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៤ មីនា ២០១២។ **E1/49.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៥ មីនា ២០១២។ សូមមើលផងដែរ E172/5 បច្ចុប្បន្នភាពទៅលើអនុស្សរណៈស្តីពីសវនាការលើឯកសារនៅដំណាក់កាលបន្ទាប់, ២ មីនា ២០១២។

[18] សូមមើល **E109/4** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំឯកសារដែលទាក់ទិននឹងដំណាក់កាលដំបូងនៃការជំនុំជម្រះលើអង្គសេចក្តី, ២២ កក្កដា ២០១១, ត្រង់កថាខណ្ឌទី៣។

[19] **E185** សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារ ដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និង ឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១, ៩ មេសា ២០១២, ទំព័រទី១៧។

[20] **E190** សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត, ៣០ មេសា ២០១២, កថាខណ្ឌទី២៤(ក)(i), ២៧, ២៨។ សូមមើលផងដែរ **E190.1** ឧបសម្ព័ន្ធ: ឯកសារថ្មីដែលបានកំណត់អត្តសញ្ញាណដោយភាគីនៅក្នុងបញ្ជីឯកសារដែលបានត្រួតពិនិត្យឡើងវិញនៅខែកក្កដា ឆ្នាំ២០១១..

១២- នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី[21]។ អង្គជំនុំជម្រះបានសម្រេចថា ទាំងយុត្តិសាស្ត្រអន្តរជាតិជាធរមាន និងទាំងក្របខណ្ឌច្បាប់ អ.វ.ត.ក មិនមានចែងអំពីសិទ្ធិផ្ទាល់មុខ ឬសិទ្ធិមិនស្មើគ្នា សម្រាប់ជនជាប់ចោទ តម្រូវឱ្យមានវត្តមានរបស់សាក្សីក្នុងពេលសវនាការ ដែលកំណត់ហេតុរបស់សាក្សីរូបនោះអាចត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះឡើយ[22]។ អង្គជំនុំជម្រះបានពិចារណាថា ក្របខណ្ឌច្បាប់ និងយុត្តិសាស្ត្ររបស់តុលាការ *ពិសេសនេះ* "វាយពីតុល្យភាពសមស្រប រវាងសិទ្ធិទទួលបានសវនាការដោយត្រឹមត្រូវរបស់ជនជាប់ចោទ និងប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី ជាអាទិ៍ដូចជាទាក់ទងនឹងភាពឆាប់រហ័សនៃការជំនុំជម្រះ"[23]។ ដោយអនុវត្តនូវគោលការណ៍នេះ អង្គជំនុំជម្រះបានសម្រេចជាសំខាន់ថា កំណត់ហេតុជាលាយលក្ខណ៍អក្សរ អាចត្រូវទទួលយកដោយពុំចាំបាច់មានការបង្ហាញខ្លួនរបស់ម្ចាស់កំណត់ហេតុនោះទេ បើសិនជាកំណត់ហេតុទាំងនោះ ពុំមានភស្តុតាងអំពីសកម្មភាព និងអំពើរបស់ជនជាប់ចោទ[24]។

១៣- នៅថ្ងៃទី១៥ ខែមិថុនា និងថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាបានដាក់សំណើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលពាក់ព័ន្ធនឹងដំណាក់កាលទី១ និងទី២ នៃការជម្លៀសប្រជាជនដោយបង្ខំ[25]។ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាបានដាក់សំណើសុំបន្ថែមទៀតដាក់ជូនអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីបន្ថែម ប្រតិចារឹក ពាក្យបណ្តឹងដែលឯកសារទាំងនោះជាប់ទាក់ទងនឹងសំណុំរឿង០០២/០១[26]។

---

[21] **E96/7** សេចក្តីសម្រេចលើកកំណត់ហេតុស្តាប់ចម្លើយសាក្សី, កថាខណ្ឌទី១៨-១៩។

[22] ឯកសារដដែលដូចខាងលើ, ត្រង់កថាខណ្ឌទី១៧។

[23] ឯកសារដដែលដូចខាងលើ, ត្រង់កថាខណ្ឌទី២០។

[24] ឯកសារដដែលដូចខាងលើ, ត្រង់កថាខណ្ឌទី២២។

[25] **E208** សំណើររបស់សហព្រះរាជអាជ្ញា សុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីពាក់ព័ន្ធនឹងការជម្លៀសប្រជាជនក្នុងដំណាក់កាលទី១, ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២; **E208/2** សំណើររបស់សហព្រះរាជអាជ្ញា សុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីពាក់ព័ន្ធនឹងការជម្លៀសប្រជាជនក្នុងដំណាក់កាលទី២ និងបញ្ហាភស្តុតាងដទៃទៀតរួមជាមួយឧបសម្ព័ន្ធសម្ងាត់ I, II, III និងឧបសម្ព័ន្ធសាធារណៈ IV។

[26] **E96/8** សំណើបន្ថែមរបស់សហព្រះរាជអាជ្ញាសុំដាក់ចំពោះមុខអង្គជំនុំជម្រះនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី ប្រតិចារឹករួមជាមួយឧបសម្ព័ន្ធសម្ងាត់ ១ ដល់ ៦ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២។

១៤- នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានកំណត់កាលបរិច្ឆេទ ត្រឹមថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ សម្រាប់ការជំទាស់ណាមួយទៅនឹងភ័ស្តុតាងដែលបានដាក់ជូន ក្នុងទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយសាក្សី ឬប្រតិចារឹក[27]។ ក្នុងខែវិច្ឆិកា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាបានស្នើតាមអ៊ីម៉ែលទៅអង្គជំនុំជម្រះ និងភាគី ថាសហព្រះរាជអាជ្ញាកំពុងតែពិនិត្យឡើងវិញលើឧបសម្ព័ន្ធទី១២ និង១៣ ដើម្បីកាត់បន្ថយចំនួនកំណត់ហេតុស្តាប់ចម្លើយ និងពាក្យបណ្តឹងដែលបានស្នើសុំ។ សហព្រះរាជអាជ្ញាបានស្នើការអនុញ្ញាតដើម្បីដាក់ចម្លើយតបរួមមួយចំពោះការជំទាស់ទាំងអស់ ទៅនឹងឧបសម្ព័ន្ធទាំងនេះ។ អង្គជំនុំជម្រះក៏បានទទួលយកសំណើសុំនោះ និងបានកំណត់ពេលចុងក្រោយសម្រាប់ចម្លើយតបរួមក្នុងរយៈពេលមួយខែ បន្ទាប់ពីការដាក់ការជំទាស់ទាំងអស់ ឬថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៣ អាស្រ័យថាមួយណាឆាប់ជាង[28]។

១៥- ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចរបស់ខ្លួនលើ **ឧបសម្ព័ន្ធ** សម្រាប់ដំណាក់កាលដំបូង **៦-១១ និង ១៤-២០** របស់សហព្រះរាជអាជ្ញា ដោយទទួលយកទាំងអស់លើកលែងតែឯកសារចំនួនប្រាំពីរដែលបានចុះបញ្ជីនៅក្នុងនោះ[29]។

១៦- កាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានធ្វើមោឃភាពនូវដីកាសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ព្រមទាំងសេចក្តីសម្រេច និងអនុស្សរណៈជាបន្តបន្ទាប់មកទៀតរបស់អង្គជំនុំជម្រះសាលាដំបូង[30]។ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសដោយផ្ទាល់មាត់អំពីសេចក្តីសម្រេចបំបែកកិច្ចនីតិវិធីថ្មី

[27] **E223/2** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងសំណើរបស់ អង្គជំនុំជម្រះសាលាដំបូង ស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់ មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភស្តុតាងគាំទ្រ (ឯកសារ E223), ១៩ តុលា ២០១២, ត្រង់កថាខណ្ឌទី១៤។

[28] **E246/1** អនុស្សរណៈ មានចំណងជើងថា "ចម្លើយតបទៅនឹងសំណើ E246 និង E185/1/1 និងសំណើផ្សេងៗមួយចំនួនពាក់ព័ន្ធនឹងឯកសារ និងពេលវេលាកំណត់", ១៣ កុម្ភៈ ២០១៣, ត្រង់កថាខណ្ឌទី១។

[29] **E185/1** សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញានិងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត, ៣ ធ្នូ ២០១២។ **E185/1.3** ឧបសម្ព័ន្ធ គ - ឯកសារដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា។

[30] **E163/5/1/13** សេចក្តីសំរេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះស្តីពីវិសាលភាពនៃសំណុំរឿងលេខ០០២/០១, ចុះថ្ងៃទី៨ កុម្ភៈ ២០១៣។

ដែលរួមបញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ នូវទីតាំងឧក្រិដ្ឋកម្មទាំងបីដដែល ដែលបានបញ្ចូលរួចហើយតាំងពីមុនមានមោឃភាពនៃដីកាបំបែកកិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះបានរក្សាសិទ្ធិចំពោះសម្អាងហេតុរបស់ខ្លួនសម្រាប់សេចក្តីសម្រេចនេះ។

## III. ច្បាប់ជាធរមាន

### ក. វិធានផ្ទៃក្នុងនៃតុលាការពិសេសនានា

១៧- វិធាន៩២*ស្ទួន* នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី (ICTY) មានចែងដោយអនុញ្ញាតឲ្យទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី ឬប្រតិចារឹក ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ បើសិនជាកំណត់ហេតុទាំងនេះមិនបានលើកអំពីសកម្មភាព និងអំពើប្រព្រឹត្តរបស់ជនជាប់ចោទទេនោះ។ វិធាននេះតម្រូវឲ្យអង្គជំនុំជម្រះពិចារណាអំពីថាតើវិធាននេះ គួរតម្រូវឲ្យសាក្សីចូលមកបង្ហាញខ្លួនដោយផ្ទាល់ ដើម្បីឲ្យគេសួរដេញដោលជាបន្ថែមពីលើការទទួលយកកំណត់ហេតុទាំងនេះទៀត ដែរឬទេ។ វិធាន៩២*ស្ទួនពីរ* បើកឲ្យអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ឬប្រតិចារឹកនានា (រួមទាំងកំណត់ហេតុ ឬប្រតិចារឹកដែលមានភស្តុតាងពីសកម្មភាព និងអំពើរបស់ជនជាប់ចោទក្នុងនោះផង) ក្នុងករណីដែលសាក្សីដែលមានវត្តមាននៅក្នុងតុលាការ បញ្ជាក់អំពីភាពត្រឹមត្រូវនៃចម្លើយនោះ ហើយដែលអាចឲ្យចៅក្រមនឹងមេធាវីការពារក្តីសួរដេញដោលបាន។ វិធាន៩២*ស្ទួនបី* បើកឲ្យអាចទទួលយកនូវចម្លើយ និងប្រតិចារឹកនានារបស់បុគ្គលទាំងឡាយដែលបានស្លាប់ហើយ ឬដែលបាត់ដានមិនអាចស្រាវជ្រាវរកឃើញ ឬដោយសារមូលហេតុទាក់ទងនឹងស្ថានភាពសុខភាព មិនអាចឲ្យពួកគាត់មកផ្តល់សក្ខីកម្មដោយផ្ទាល់មាត់បាន។

### ខ. ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

១៨- ដូចដែលបានធ្វើការកត់សម្គាល់នៅក្នុងប្រវត្តិនៃនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថាវិធានទាំងនេះដែលសម្រាប់ធ្វើឲ្យមានតុល្យភាពដ៏ត្រឹមត្រូវមួយរវាងសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវ នឹងការចាំបាច់ដើម្បីធានាឲ្យកិច្ចដំណើរការនីតិវិធី ត្រូវបាន

ប្រព្រឹត្តទៅដោយឆាប់រហ័ស។ ការយកវិធានទាំងនេះ នឹងករណីយុត្តិសាស្ត្រនានាដែលពាក់ព័ន្ធរបស់តុលាការ *ពិសេស* នានា មកធ្វើជាមគ្គុទេសណ៍នាំអង្គជំនុំជម្រះចេញសេចក្តីសម្រេចដូចតទៅនេះ៖

ក. “កំណត់ហេតុជាលាយលក្សណ៍អក្សរ ឬប្រតិចារិកទាំងឡាយដែលបានស្នើសុំឱ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះសម្រាប់យកទៅធ្វើជាភ័ស្តុតាងស្តីពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទណាម្នាក់ដូចដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ”[មានអញ្ញត្រកម្មតិចតួច] ត្រូវបានចាត់ទុកថា “ច្បាប់មិនអនុញ្ញាតឱ្យទេ” អនុលោមតាមវិធាន៨៧(៣)(ឃ)នៃវិធានផ្ទៃក្នុង ហើយមិនអាចទទួលយកបានសម្រាប់គោលបំណងនេះឡើយ លុះត្រាតែក្រុមមេធាវីការពារក្តីបានទទួលនូវការយល់ព្រមអនុញ្ញាតឱ្យនូវឱកាស ដើម្បីធ្វើការសួរដេញដោលចំពោះម្ចាស់នៃកំណត់ហេតុស្តាប់ចម្លើយសាក្សី ឬប្រតិចារិកទាំងនេះនៅក្នុងតុលាការ”[31] ។

ខ. “នៅក្នុងករណីផ្ទុយទៅវិញ បើសិនជាកំណត់ហេតុត្រូវបានយកទៅធ្វើជាភស្តុតាងបង្ហាញអំពីបញ្ហាផ្សេងទៀតក្រៅពីអំពើ ឬការប្រព្រឹត្តរបស់ជនជាប់ចោទ (នឹងត្រូវចាត់ទុកថា មានការជាប់ទាក់ទង និងអាចឱ្យជឿទុកចិត្តបាន *ដោយគ្រាន់តែឃើញមួយក្រឡេកដំបូង* ហើយម្យ៉ាងទៀតមិនត្រូវបានបដិសេធអនុលោមតាមវិធាន៨៧(៣)នៃវិធានផ្ទៃក្នុង) អង្គជំនុំជម្រះនឹងត្រូវរកឱ្យឃើញថា ភ័ស្តុតាងរបស់បុគ្គលដែលមានទម្រង់ជាកំណត់ហេតុជាលាយលក្សណ៍អក្សរ ឬជាប្រតិចារឹក គឺអាចឱ្យទទួលយកបានដោយពុំចាំបាច់តម្រូវឱ្យសាក្សីចូលខ្លួននៅក្នុងសវនាការឡើយ ហើយនៅក្នុងលក្ខខណ្ឌមួយចំនួនអាចពឹងផ្អែកលើឯកសារទាំងនេះបាន...[]កត្តាដែលគាំទ្រដល់ការទទួលយកនិងដែលផ្តល់នូវតម្លៃភរនីយភាពមួយចំនួន ដែលហេតុដូចនេះ ត្រូវធ្វើការថ្លឹងថ្លែងជាមួយនឹងភ័ស្តុតាង ...ដែលរួមបញ្ចូលទាំងអំពីថាតើភ័ស្តុតាងនេះ៖

i. គឺជាភ័ស្តុតាងដែលមានលក្ខណៈត្រួតគ្នាជាមួយនឹងភ័ស្តុតាង ដែលសាក្សីផ្សេងទៀតនឹងផ្តល់ឱ្យ ឬបានផ្តល់ឱ្យ តាមរយៈការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ អំពីអង្គហេតុដែលស្រដៀងគ្នានេះ ដែរ ឬទេ?

ii. មានជាប់ទាក់ទងគ្នាជាមួយនឹងប្រវត្តិដើមនៃប្រវត្តិសាស្ត្រ, នយោបាយ ឬយោធា មានជាប់ពាក់ព័ន្ធនឹងភ័ស្តុតាងនៃទីតាំងឧក្រិដ្ឋកម្ម ឬយកទៅធ្វើជាភ័ស្តុតាងអំពីធាតុផ្សំដែល

---

[31] ឯកសារលេខ **E96/7** សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយសាក្សី,ត្រង់កថាខណ្ឌទី២២។

ជាចំណុចចាប់ផ្ដើមនៃឧក្រិដ្ឋកម្មអន្តរជាតិ (ដូចជា អំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ឬលក្ខណៈទូលំទូលាយនិងជាប្រព័ន្ធនៃការវាយប្រហារ) ដែរ ឬទេ”។

iii. មានការវិភាគជាទូទៅ ឬផ្អែកលើស្ថិតិស្ដីពីសមាសភាពនៃក្រុមជាតិពន្ធុនៃប្រជាជននៅតាមទីកន្លែងនានាដែលនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរមាននិយាយទាក់ទងដល់ ដែរ ឬទេ។

iv. មានជាប់ទាក់ទងទៅនឹងផលប៉ះពាល់នៃឧក្រិដ្ឋកម្មនានាទៅលើជនរងគ្រោះដែរ ឬទេ។

v. មិនអាចមានលទ្ធភាពក្នុងការដាក់ឱ្យធ្វើការតទល់គ្នាបានទេ ពីព្រោះម្ចាស់នៃកំណត់ហេតុឬប្រតិចារិកនេះ បន្ទាប់មកទៀតបានស្លាប់បាត់ទៅហើយ ឬមានភាពសមហេតុសមផលថា ទោះបីខំស្វែងរកដោយយកចិត្តទុកដាក់ ក៏រកលែងឃើញដែរ ឬក៏ដោយសារតែស្ថានភាពសុខភាពដែលមិនអាចឱ្យមកផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់បាន”[32]។

១៩- លើសពីនេះ អង្គជំនុំជម្រះងបានសម្រេចថែមទៀតថា កំណត់ហេតុដែលធ្វើឡើងដោយ កសចស គឺមានសិទ្ធិត្រូវបានសន្មត់ថាអាចឱ្យជឿទុកចិត្តបាន ហើយការជំទាស់ទាំងឡាយទៅនឹងកំណត់ហេតុទាំងនេះ តោងតែមានការចោទប្រកាន់អំពី វិការៈផ្សេងៗដែលមានលក្ខណៈពិសេសគ្រប់គ្រាន់ និងមានភាពជាប់ទាក់ទងយ៉ាងច្បាស់លាស់ទៅនឹងការជំនុំជម្រះក្ដី[33]។ អង្គជំនុំជម្រះបានសម្រេចថា កំណត់ហេតុស្ដាប់សាក្សីទាំងឡាយដែលធ្វើឡើងដោយអង្គភាពនានាក្រៅពី អវតក អង្គជំនុំជម្រះបានថ្លែងថា ឯកសារទាំងនេះ គឺមិនមានសិទ្ធិអាចឱ្យសន្មតថាអាចឱ្យជឿទុកចិត្តបានដូចគ្នានោះឡើយ ក៏ប៉ុន្តែនៅតែអាចត្រូវបានទទួលយកដដែល[34]។

២០- ទាក់ទងទៅនឹងកំណត់ហេតុរបស់សាក្សីនានា ដែលមិនអាចមានលទ្ធភាពចូលមកបង្ហាញខ្លួនដើម្បីផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់បាននោះ អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់ថាគោលការណ៍នានាជាធរមានដែលស្ថិតនៅក្នុងកម្រិតអន្តរជាតិបានអនុញ្ញាតឱ្យអាចទទួលយកភ័ស្តុតាងរបស់សាក្សីទាំងឡាយ ដែលបានស្លាប់ទៅហើយ ឬភាពសមហេតុសមផលថាទោះជាខំស្វែងរកដោយយកចិត្តទុកដាក់ក៏រកលែង

[32] ឯកសារលេខ **E96/7** សេចក្ដីសម្រេចលើកំណត់ហេតុស្ដាប់ចម្លើយសាក្សី,គ្រង់កថាខណ្ឌទី២៣ និង២៤។

[33] ឯកសារលេខ **E96/7** សេចក្ដីសម្រេចលើកំណត់ហេតុស្ដាប់ចម្លើយសាក្សី,គ្រង់កថាខណ្ឌទី២៦។

[34] ឯកសារលេខ **E96/7** សេចក្ដីសម្រេចលើកំណត់ហេតុស្ដាប់ចម្លើយសាក្សី,គ្រង់កថាខណ្ឌទី២៩។

ឃើញដែរ ឬអ្នកដែលដោយសារមូលហេតុមកពីស្ថានភាពសុខភាពខាងផ្លូវកាយ ឬខាងសតិបញ្ញាស្មារតី ពុំអាចមានលទ្ធភាពមកផ្តល់សក្ខីកម្មដោយផ្ទាល់មាត់បាន"[35]។ បើសិនជាកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនេះលើកឡើងបង្ហាញភ័ស្តុតាងអំពីអំពើ និងសកម្មភាពរបស់ជនជាប់ចោទនោះ គឺការទទួលយកនូវកំណត់ហេតុទាំងនេះមិនត្រូវបានរារាំងទេ ក៏ប៉ុន្តែផ្ទុយទៅវិញ ធាតុផ្សំគឺត្រូវបានចាត់ទុកថាជាកត្តាមួយដែលត្រូវយកមកធ្វើការថ្លឹងថ្លែងគ្នាប្រឆាំងនឹងការទទួលយក[36]។

## គ. ការសម្រេចបន្ថែមទៀតរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងអំពីប្រតិចារឹកទាំងឡាយនៃសំណុំរឿងលេខ០០១

២១- អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា នៅក្នុងប្រតិចារឹកទាំងឡាយនៃសំណុំរឿងលេខ០០១ មានសញ្ញាបង្ហាញអំពីភាពអាចឲ្យជឿទុកចិត្តបាន ជាប់មកជាមួយស្រាប់ [37]ហើយបានសម្រេចបន្ថែមទៀតថា៖

> "ក្របខណ្ឌច្បាប់នៃបណ្តាតុលាការដែលធ្វើឲ្យទៅជាលក្ខណៈអន្តរជាតិផ្សេងទៀតបាន(sic) ដោយអាស្រ័យទៅលើស្ថានភាពមួយចំនួន ក៏គេអនុញ្ញាតឲ្យប្រើប្រតិចារិកនានាផងដែរ...បើសិនជាភ័ស្តុតាងរបស់បុគ្គលនោះនៅក្នុងសវនាការណាមួយក្រោយមកទៀតបាន លើកឡើងនូវសក្ខីកម្មកាលពីលើកមុនដដែលៗសារជាថ្មីម្តងទៀត ដែលទោះបីជាត្រូវបានគេយកទៅធ្វើជាភ័ស្តុតាងបង្ហាញពីអំពើ និងសកម្មភាពរបស់ជនជាប់ចោទក៏ដោយ។ ដើម្បីរក្សាការពារភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធីនៃសវនាការលើសំណុំរឿងលេខ០០២ ដោយអនុលោមទៅតាមសេចក្តីណែនាំនេះ ភាគីនានាអាចស្នើសុំឲ្យទទួលយកនូវប្រតិចារិកនៃភ័ស្តុតាងដែលមកពីសំណុំរឿងលេខ០០១បាន បើសិនជាការស្តាប់ភ័ស្តុតាងរបស់បុគ្គលនោះឡើងវិញម្តងទៀតទំនងជាធ្វើឲ្យមានភាពច្រំដែលៗជាន់គ្នាជាមួយនឹងភ័ស្តុតាងរបស់ពួកគេកាលពីលើកមុន *បើសិនជាសាក្សីនោះអាចមានលទ្ធភាពចូលមកបង្ហាញខ្លួននៅក្នុងតុលាការដើម្បីឲ្យភាគីបដិបក្សសួរដេញដោល និងបើសិនជាគាត់ផ្តល់ភ័ស្តុតាងថា ប្រតិចារិកដែលចោទជាបញ្ហានេះឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវអំពីអ្វីដែលសាក្សីមុខជានឹងនិយាយ បើសិនជាត្រូវបានសួរដេញដោល*"។(**សង្កត់ន័យបន្ថែមដោយអក្សរទ្រេត**)[38]

---

[35] ឯកសារលេខ **E96/7** សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយសាក្សី,ត្រង់កថាខណ្ឌទី៣២។

[36] ឯកសារលេខ **E96/7** សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយសាក្សី,ត្រង់កថាខណ្ឌទី៣២។

[37] ឯកសារលេខ **E96/7** សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយសាក្សី, ត្រង់កថាខណ្ឌទី២៩។

[38]ឯកសារលេខ **E96/7** សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយសាក្សី,ត្រង់កថាខណ្ឌទី៣១។

សម្រាប់ការបញ្ចប់ សហព្រះរាជអាជ្ញាសូមកត់សម្គាល់ថា បទប្បញ្ញត្តិរបស់តុលាការ*ពិសេស*នានាដែលអង្គជំនុំជម្រះបានពឹងផ្អែកលើនៅក្នុងអត្ថបទខ្លីៗខាងលើនេះ គឺទាក់ទង*ទាំង*ប្រតិចារឹកផង និង*ទាំង*កំណត់ហេតុស្តាប់ចម្លើយសាក្សីចម្លើយផង[39]។

២២- បន្ទាប់ពីការសម្រេចខាងលើនេះ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនទាក់ទងនឹង**ឧបសម្ព័ន្ធពីទី៦-១១ និងពីទី១៤-២០** អង្គជំនុំជម្រះបានទទួលយកនូវប្រតិចារឹកនៃសំណុំរឿងលេខ០០១មួយចំនួន(ឧបសម្ព័ន្ធទី១១)ក្នុងនោះមានភស្តុតាងដែលបង្ហាញអំពើ និងសកម្មភាពរបស់ជនជាប់ចោទ[40]។ ក្នុងការធ្វើដូច្នេះ អង្គជំនុំជម្រះហាក់ដូចជាបានផ្តល់នូវជម្រើសមួយផ្សេងទៀត សម្រាប់ជំនួសឲ្យនីតិវិធីដូចដែលបានរៀបរាប់នៅក្នុងកថាខណ្ឌទី១៧ និង២០ខាងលើ។

២៣- តាមស្មារតីនៃសេចក្តីសម្រេចរបស់ខ្លួនចុងក្រោយនេះលើឧបសម្ព័ន្ធទី១១ សហព្រះរាជអាជ្ញាមិនបានធ្វើការពិនិត្យឡើងវិញដូចគ្នានេះទៅលើប្រតិចារឹកដើម្បីកំណត់ពីអត្តសញ្ញាណនៃភស្តុតាង ដែលទាក់ទងនឹងអំពើ ឬសកម្មភាពរបស់ជនជាប់ចោទដូចដែលបានធ្វើទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី និងពាក្យបណ្តឹងឡើយ (សូមអានផ្នែកទី IV ខាងក្រោម)[41]។ ក៏ប៉ុន្តែសហព្រះរាជអាជ្ញាត្រៀមខ្លួនអនុវត្តតាមបញ្ជារបស់អង្គជំនុំជម្រះជាដដែល បើសិនជាយល់ឃើញថា មានវិធីសាស្ត្រណាមួយ

---

[39] សូមអានផ្នែកទីIII(ក) ខាងលើ – វិធាន៨២ស្ទួនពីរ។

[40] ឯកសារលេខ**E185/1** សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារនានាដែលបានស្នើសុំឲ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងឧបសម្ព័ន្ធទី ក៦-ក១១ និង ក១៤-ក២០របស់សហព្រះរាជអាជ្ញា និងដោយភាគីផ្សេងទៀត, ចុះថ្ងៃទី៣ ធ្នូ២០១២, ត្រង់កថាខណ្ឌទី៥(v) និង៥(ix), ហើយនិង ទី១៧។ ប្រតិចារិកទាំងឡាយដែលត្រូវបានទទួលយករួចហើយៗ ដែលក្នុងនោះមានភស្តុតាង ស្តីពីអំពើនិងការប្រព្រឹត្តរបស់ជនជាប់ចោទ, ដែលរួមទាំងឯកសារលេខ **D288/4.26.1 (E3/2983)** – សូមអានសេចក្តីយោងទៅលើជនជាប់ចោទ ដែលនៅត្រង់លេខ ERNs 00334501, 00334509, 00334512 និង 00334519, ឯកសារលេខ**D288/4.27.1 (E3/2984)** – សូមអានសេចក្តីយោងទៅលើជនជាប់ចោទ ដែលនៅត្រង់លេខ ERNs 00336866-7, 00336869, 00336888-9, 00336932-3,និងឯកសារលេខ **D288/4.74.1 (E3/2985)** – សូមអានសេចក្តីយោងទៅលើជនជាប់ចោទ ដែលនៅត្រង់លេខ ERN 00378508, 00378511-2, 00378517-9, និងលេខ 00378536។

[41] សហព្រះរាជអាជ្ញា សូមកត់សម្គាល់ថា គឺជាការមិនស្របគ្នាទេ ដែលមានកម្រងនៃការជ្រើសរើសប្រតិចារិកមួយដែលត្រូវបានទទួលយកដោយពុំមានការបញ្ជាក់ពីអត្តសញ្ញាណនៃការជ្រើសរើសយកដែលទាក់ទងទៅនឹងអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ និងការជ្រើសរើសលើកទីពីរដែលត្រូវបានធ្វើវិភាគដូចនេះរួចហើយ។ ហេតុដូចនេះ ក្នុងហេតុផលដើម្បីឲ្យមានការឯកភាពគ្នា សហព្រះរាជអាជ្ញា មិនបានគូសរំលេចពណ៌លើចំណែកណាមួយនៃប្រតិចារិកដែលសេសសល់នៅក្នុងឧបសម្ពន្ធទី១១ដែលអាចមានការជាប់ទាក់ទងនឹងទៅនឹងអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទឡើយ។ ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាបានត្រៀមរៀបចំខ្លួនដើម្បីកំណត់អត្តសញ្ញាណនៃផ្នែកទាំងនោះនៃប្រតិចារិកដែលនៅក្នុងឧបសម្ព័ន្ធទី១១ នៅក្នុងរយៈពេលអប្បបរមា ៧ថ្ងៃយ៉ាងយូរ បើសិនជាអង្គជំនុំជម្រះស្នើសុំឲ្យធ្វើដូច្នេះ។

ផ្សេងទៀតដែលមានលក្ខណៈសមស្របជាងនេះ សម្រាប់ឯកសារសេសសល់ ដែលមាននៅក្នុងឧបសម្ព័ន្ធទី១១។

២៤- ក្នុងករណីណាក៏ដោយ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះ សូមមេត្តាទទួលយកនូវឯកសារសេសសល់ដែលមាននៅក្នុងឧបសម្ព័ន្ធទី១១។ សហព្រះរាជអាជ្ញាស្នើសូមកុំឲ្យមានការកាត់បន្ថយថែមទៀតចេញពីក្នុងឧបសម្ព័ន្ធនេះ ដោយសារតែភាពគួរឲ្យជឿទុកចិត្តបាននៃភ័ស្តុតាង ដែលមានកំរិតខ្ពស់ និងភាពជាប់ទាក់ទងគ្នានៃឯកសារនេះទៅនឹងការរកឃើញនានា អំពីសហកម្មឧក្រិដ្ឋកម្មរួម, គោលនយោបាយ, និងរចនាសម្ព័ន្ធនៃសិទ្ធិអំណាចរបស់បកក/កម្ពុជាប្រជាធិបតេយ្យ។ ការយកចេញនូវប្រតិចារឹកនានាក៏អាចធ្វើឲ្យប៉ះពាល់ដល់ការយល់ឲ្យបានត្រឹមត្រូវអំពីភ័ស្តុតាងផ្សេងទៀត នៃមន្ទីរស-២១ដែលត្រូវបានទទួលយករួចហើយផងដែរ (នៅក្នុងឧបសម្ព័ន្ធទី៩, ១០ និង ១១) គួរកត់សម្គាល់ថាការកាត់បន្ថយចំនួនដ៏ច្រើនពីក្នុងភ័ស្តុតាងជាសក្ខីកម្មដែលទាក់ទងនឹងមន្ទីរស-២១ នឹងត្រូវទទួលរងផលប៉ះពាល់ ព្រោះសហព្រះរាជអាជ្ញាបានដកកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលពាក់ព័ន្ធនឹងមន្ទីរស-២១ អស់ចំនួនជាងមួយរយចេញពីក្នុងឧបសម្ព័ន្ធទី ១២ រួចមកហើយ។

## ឃ. ចម្លើយតបទៅនឹងការជំទាស់ផ្សេងៗរបស់ក្រុមមេធាវីការពារក្តី

២៥- ក្រុមមេធាវីការពារជនជាប់ចោទ នួន ជា និង អៀង សារី បានលើកឡើងនូវការជំទាស់មួយចំនួនទៅនឹងការសម្រេចរបស់អង្គជំនុំជម្រះ ហើយស្វែងរកសុំឲ្យមានការបញ្ជាក់បំភ្លឺអំពីការសម្រេចរបស់អង្គជំនុំជម្រះ ជាពិសេសដោយសារការជាប់ទាក់ទងគ្នាទៅនឹងការអនុវត្តនៃវិធាន៩២*ស្ទួន* នៃវិធានផ្ទៃក្នុងរបស់តុលាការ ICTY [42] ការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនានាដោយពុំមានការចូលរួមរបស់សាក្សី នៅពេលដែលក្នុងកំណត់ហេតុទាំងនោះមានទាំងព័ត៌មានដែលអាចទទួលយកបានផង និងទាំងព័ត៌មានដែលមិនអាចទទួលយកបានផង[43] និងប្រភេទផ្សេងៗនៃព័ត៌មានដែលបង្កើតបានជាភ័ស្តុតាងអំពីអំពើ និងសកម្មភាពរបស់ជនជាប់ចោទ[44]។ សហព្រះរាជអាជ្ញាសូមធ្វើការកត់សម្គាល់ចំពោះអំណះអំណាងទាំងនេះ ហើយបានបង្ហាញដោយត្រួសៗអំពីធាតុផ្សំមួយចំនួននៃព័ត៌មានទាំងនេះ

[42] ឯកសារលេខ **E96/8/1** ការឆ្លើយតបជាបឋមទៅនឹងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញា សុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារិក, ចុះថ្ងៃទី៨ វិច្ឆិកា ២០១២ ត្រង់កថាខណ្ឌទី៦-១៣។

[43] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌពីទី១៥-១៦។

[44] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌពីទី២៣-៣៦។

ដូចខាងក្រោម ដោយគ្រាន់ធ្វើក្នុងកំរិតមួយដើម្បីពន្យល់អំពីវិធីសាស្ត្រក្នុងការពិនិត្យមើលឡើងវិញលើឧបសម្ព័ន្ធទី១២ និងទី១៣តែប៉ុណ្ណោះ។ ដើម្បីជៀសវាងកុំឲ្យមានការលើកឡើងជាថ្មីម្តងទៀតនូវអំណះអំណាងច្រំដែលៗនោះ សហព្រះរាជអាជ្ញាសូមរក្សាគោលជំហររបស់ខ្លួនស្តីពីបញ្ហានានាទាក់ទងនឹងអង្គច្បាប់ ហើយនឹងធ្វើការឆ្លើយតបឲ្យបានពេញលេញ បន្ទាប់ពីរាល់ការជំទាស់ទាំងអស់របស់ក្រុមមេធាវីការពារក្តីត្រូវបានដាក់រួច[45]។

## IV. អភិក្រមរបស់សហព្រះរាជអាជ្ញានៅក្នុងការពិនិត្យកែសម្រួលឡើងវិញលើឧបសម្ព័ន្ធទី ១២ និង ១៣

### ក. ការជ្រើសរើស/ ការកំណត់អត្តសញ្ញាណនៃភស្តុតាងដែលទាក់ទងនឹងជនជាប់ចោទ

២៦- ដូចបញ្ជាក់ក្នុងកថាខណ្ឌទី២ខាងលើ បន្ទាប់ពីការពិនិត្យកែសម្រួលឡើងវិញយ៉ាងល្អិតល្អន់ សហព្រះរាជអាជ្ញាបានកាត់បន្ថយចំនួននៃកំណត់ហេតុ និងពាក្យបណ្តឹងដែលដាក់នៅក្នុងបញ្ជីក្នុងឧបសម្ព័ន្ធទី១២ និង១៣ របស់ខ្លួន ជាង៤៣ភាគរយ។ ឥឡូវនេះកំណត់ហេតុ និងពាក្យបណ្តឹងសរុបចំនួន១០៤០ ត្រូវបានស្នើសុំ។ ដូចដែលបានកត់សម្គាល់នៅក្នុងកថាខណ្ឌទី២ ឧបសម្ព័ន្ធទី១២ ដែលបានពិនិត្យកែសម្រួលឡើងវិញ ដែលក្នុងនោះរួមមានកំណត់ហេតុស្តាប់ចម្លើយសាក្សីថ្មីចំនួន១៧ ដែលមកទល់ត្រឹមពេលដាក់បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាដោយអនុលោមតាមវិធាន៨០(៣)នៃវិធានផ្ទៃក្នុង មិនទាន់អាចឲ្យរកបាននៅឡើយទេ។

២៧- ការជ្រើសរើសកំណត់ហេតុ និងពាក្យបណ្តឹងទាំងឡាយដែលមាននៅក្នុង ឧបសម្ព័ន្ធនានាដែលបានពិនិត្យកែសំរួលឡើងវិញរួច គឺដោយផ្អែកលើវិធីសាស្ត្រដូចតទៅនេះ៖

---

[45] ឯកសារលេខ**E246/1** អនុស្សរណៈ៖ ចម្លើយតបទៅនឹងសំណើ E246 និង E185/1/1 និងផ្សេងៗមួយចំនួនពាក់ពន្ធនឹងឯកសារ និងពេលវេលាកំណត់, ចុះថ្ងៃទី១៣ កុម្ភៈ២០១៣, ត្រង់កថាខណ្ឌទី១។

ក. រាល់កំណត់ហេតុស្តាប់ចម្លើយសាក្សី និងពាក្យបណ្តឹងទាំងឡាយ ដែលក្នុងនោះមានភ័ស្តុតាងពាក់ព័ន្ធផ្ទាល់នឹងសំណុំរឿងលេខ០០២/០១ បញ្ហាទាំងនោះត្រូវបានដាក់បញ្ចូលរួចហើយ។

ខ. គំរូនៃកំណត់ហេតុ និងពាក្យណ្តឹងទាំងឡាយដែលជាតំណាង ត្រូវបានដាក់បញ្ចូលសម្រាប់ទីតាំងឧក្រិដ្ឋកម្មនានាដែលមាននៅក្នុងដីកាដំណោះស្រាយ ដែលមិនបង្កើតជាផ្នែកនៅក្នុងសំណុំរឿងលេខ០០២/០១[46]។ និង

គ. កំណត់ហេតុផ្សេងទៀត ដែលត្រូវបានលែងចាត់ទុកថាជាប់ពាក់ព័ន្ធនឹងសំណុំរឿងលេខ ០០២/០១តទៅទៀត ត្រូវបានដកចេញ។

២៨- សហព្រះរាជអាជ្ញាសូមជូនជាយោបល់សម្រាប់ពិចារណាថា ការទទួលយកនូវកំណត់ហេតុ (ស្តាប់ចម្លើយសាក្សី) និងពាក្យបណ្តឹងទាំងនេះគឺស្របគ្នាទាំងស្រុងទៅនឹងគោលការណ៍ដែលបានគូសបញ្ជាក់ដោយអង្គជំនុំជម្រះ (ផ្នែកទីIII(ខ)ខាងលើ)។ នៅក្នុងឯកសារទាំងនេះមានភ័ស្តុតាងសំខាន់ៗជាច្រើនទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្ម និងភ័ស្តុតាងអំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្មទាំងនេះទៅលើជនរងគ្រោះ។ ឯកសារទាំងនេះគឺជាលក្ខណៈត្រួតពីលើគ្នា ដោយសារភាពស៊ីសង្វាក់គ្នាទៅវិញទៅមកនៃភ័ស្តុតាងជាសក្ខីកម្ម ជាមួយនឹងភ័ស្តុតាងដទៃទៀតដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ។ ឯកសារទាំងនេះក៏មានការទាក់ទងទៅនឹងធាតុផ្សំនៃឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនឹងបរិបទផងដែរ (ឧទាហរណ៍ដូចជា គោលនយោបាយ និងរចនាសម្ព័ន្ធរបស់ បកក/កម្ពុជា ប្រជាធិបតេយ្យ)។ មានកំណត់ហេតុជាច្រើន ក៏បានផ្តល់នូវភ័ស្តុតាងភរនីយហេតុស្តីពីប្រវត្តិដើមដែលនាំឲ្យមានឧក្រិដ្ឋកម្មទាំងនេះ។

២៩- មូលហេតុបន្ថែម ដែលនាំឲ្យមានការដាក់បញ្ចូលនូវគំរូដែលតំណាងនានា ដូចដែលបានរៀបរាប់ក្នុងកថាខណ្ឌ២៦(ខ)ខាងលើនោះ គឺដើម្បីជួយដល់សហព្រះរាជអាជ្ញាក្នុងការបំពេញការទទួលខុសត្រូវរបស់
ខ្លួនក្នុងការបង្ហាញភ័ស្តុតាងអំពីអត្ថិភាពនៃគោលនយោបាយនានាដែលបង្កើតបានជាផ្នែកនៃការចោទ

[46] គំរូទាំងនេះគឺជាកំណត់ហេតុទាំងឡាយដែលអ្នកធ្វើកំណត់ហេតុទាំងនេះ ត្រូវបានសហព្រះរាជអាជ្ញាបានស្នើសុំឲ្យមកធ្វើជាសាក្សីក្នុងសវនាការដើម្បីផ្តល់សក្ខីកម្មអំពីទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងសំណុំរឿងលេខ០០២។ ការធ្វើដូចនេះ ពួកគេគឺជាតំណាងឲ្យបណ្តុំនៃភស្តុតាងដែលធំជាង ដែលមានស្រាប់សម្រាប់ទីតាំងឧក្រិដ្ឋកម្មនីមួយៗ។

ប្រកាន់អំពីសហកម្មឧក្រិដ្ឋកម្មរួម និង (ដែលជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) អំពីលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធនៃការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលនៃប្រទេសកម្ពុជា។ អង្គជំនុំជម្រះបានដាក់បញ្ចូលនូវបញ្ហាទាំងនេះនៅក្នុងការជំនុំជម្រះក្តីនាពេលបច្ចុប្បន្ននេះ[47]។ សហព្រះរាជអាជ្ញា ជូនជាយោបល់សម្រាប់ពិចារណាថា ការទទួលយកនូវគំរូសម្រាប់តំណាងឲ្យកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយចំនួនតូចដែលទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនីមួយៗ ដែលមាននៅក្នុងដីកាដំណោះស្រាយ គឺជាការសមហេតុសមផលផងនិងចាំបាច់ផង។ ឯកសារទាំងនេះនឹងធ្វើឲ្យមានភាពស៊ីសង្វាក់គ្នាទៅវិញទៅមកនៃភស្តុតាង អំពីលក្ខណៈ ភាពជាប្រព័ន្ធ និងវិសាលភាពនៃឧក្រិដ្ឋកម្មទាំងឡាយដែលហេតុដូចនេះគឺជួយគាំទ្រដល់ការបញ្ជាក់ពីការពិត ដែលទាក់ទងទៅនឹងគោលនយោបាយដូចដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ។

៣០- ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការយោង មានជួរបញ្ឈរមួយដែលមានចំណងជើងថា "ចំណុចជាសារវន្តនៃការជាប់ពាក់ព័ន្ធ" ត្រូវបានដាក់បន្ថែមនៅក្នុងឧបសម្ពន្ធទី១២ និង១៣ (សូមមើលផងដែរ ឧបសម្ព័ន្ធ ក សម្រាប់ខ្លឹមសារទូទៅ)។ នេះគឺជាការផ្តល់នូវការបញ្ជាក់ជាទូទៅមួយ អំពីមូលហេតុសារវន្តដែលនាំឲ្យមានការដាក់បញ្ចូលនូវកំណត់ហេតុនីមួយៗ។ ប៉ុន្តែទោះដោយមធ្យោបាយណាក៏ដោយ <u>មិនគួរ</u>ចាត់ទុក<u>ទាល់តែសោះ</u>ថា គឺជាមូលហេតុតែមួយ ពាក់ព័ន្ធនោះឡើយ។ ឧទាហរណ៍ដូចជាកំណត់ហេតុទាំងឡាយដែលពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ នឹងមានមន្ទីរសន្តិសុខនោះ ដែលត្រូវបានសម្គាល់ថាជាចំណុចសារវន្តនៃការជាប់ពាក់ព័ន្ធ ពីព្រោះកំណត់ហេតុទាំងនេះជាគំរូដែលតំណាងឲ្យទីតាំងឧក្រិដ្ឋកម្មនោះ។ ព្រមពេលជាមួយគ្នានោះ កំណត់ហេតុទាំងនេះអាចជាប់ទាក់ទងទៅនឹងការរកឃើញអំពីគោលនយោបាយ,សហកម្មឧក្រិដ្ឋកម្មរួម, រចនាសម្ព័ន្ធនៃសិទ្ធិអំណាច។

៣១- ដូចដែរបានកត់សម្គាល់នៅក្នុងកថាខណ្ឌទី២ កំណត់ហេតុស្តាប់ចម្លើយសាក្សី និងពាក្យបណ្តឹងចំនួន ១០៤០ បានដាក់បញ្ជូនក្នុងសេចក្តីសន្និដ្ឋាននេះ ដោយរួមមានឯកសារចំនួន១៧០ (កំណត់ហេតុស្តាប់ចម្លើយសាក្សីមានចំនួន១៦៩ និងពាក្យបណ្តឹងចំនួន១) ដែលរួមមានកំណត់ហេតុស្តាប់ចម្លើយសាក្សី

[47] សូមអាន ឧទាហរណ៍ដូចជា ឯកសារលេខ **E124/7.3** បញ្ជីកថាខណ្ឌ និងចំណែកនៃដីកាដំណោះស្រាយ ដែលជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿងលេខ០០២/០១, ដែលត្រូវបានធ្វើការកែប្រែបន្ថែមទៀតដោយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីបញ្ហាកាយសម្បទា និងសតិបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (ឯកសារលេខE138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាដែលសុំឲ្យឲ្យដាក់បញ្ចូលនូវទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះក្តីក្នុងសំណុំរឿងលេខ ០០២/០១ (ឯកសារលេខE163)។

ដែលបានផ្តល់សក្ខីកម្មរួចហើយក្នុងសវនាការ (ផ្នែក ក នៃឧបសម្ព័ន្ធកែសម្រួលឡើងវិញនេះ)។ ឯកសារបន្ថែមទៀតចំនួន១១(ដប់មួយ)ទៀត គឺជាកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានទទួលមរណភាព ឬដែលអង្គជំនុំជម្រះបានចាត់ទុកថា មិនអាចមានលទ្ធភាពចូលមកបង្ហាញខ្លួនដើម្បីផ្តល់សក្ខីកម្មបាន(ផ្នែក ឃ នៃឧបសម្ព័ន្ធទី១២ ដែលបានពិនិត្យកែសំរួលឡើងវិញ)។ ឯកសារទាំងនេះ គឺសុទ្ធតែអាចទទួលយកបាន *ដោយគ្រាន់តែឃើញមួយក្រឡេកភ្នែកដំបូង* ដោយអនុលោមតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។

៣២- ចំពោះកំណត់ហេតុស្តាប់ចម្លើយសាក្សី និងពាក្យបណ្តឹងដែលនៅសេសសល់ចំនួន៨៥៩ មានឯកសារសរុបចំនួន២២០ (១៩៤ជាកំណត់ហេតុស្តាប់ចម្លើយសាក្សី និងពាក្យបណ្តឹងចំនួន២៦) ដែលមានភស្តុតាងបញ្ជាក់អំពីអំពើ និងសកម្មភាពរបស់ជនជាប់ចោទ។ សហព្រះរាជអាជ្ញាធ្លាប់បានបង្កើតជាសំណៅអេឡិចត្រូនិកអំពីឯកសារទាំងនេះ ដែលនៅក្នុងនោះ ផ្នែកទាំងឡាយដែលមានផ្ទុកនូវភស្តុតាងស្តីពីអំពើ និងសកម្មភាពរបស់ជនជាប់ចោទត្រូវបានកំណត់អត្តសញ្ញាណដោយកំណត់យកពណ៌ក្រហម (កំណត់ហេតុទាំងនេះត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីនៅក្នុងផ្នែក ខ និង គ នៃឧបសម្ព័ន្ធទី១២ និង១៣ដែលបានកែសម្រួល និងត្រូវបានកំណត់អត្តសញ្ញាណដោយអក្សរ "Y" នៅក្នុងតារាងស្តីពី "កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានកោសលុប (Y/N)" ក្នុងតារាងទាំងនេះ[48]។ ការណ៍នេះ នឹងជួយដល់អង្គជំនុំជម្រះ ដើម្បីអាចមានលទ្ធភាពក្នុងការពិនិត្យមើលឯកសារនានាឡើងវិញ និងក្នុងការពិនិត្យពិចារណាថា តើផ្នែកដែលមានគូសកំណត់ គឺជាផ្នែកដែលមិនអាចទទួលយកបាន។ ការណ៍នេះក៏ជួយផងដែរដល់មេធាវីការពារក្តីក្នុងការជំទាស់ជាក់លាក់ ប្រសិនបើគេជ្រើសរើសធ្វើដូច្នេះ។ វិធីសាស្ត្រនេះត្រូវបានទទួលយល់ព្រមនៅតុលាការ ICTY[49]។ ឯកសារទាំងនេះត្រូវបានដាក់

[48] ចំនួនជាក់ស្តែងនៃឯកសារគឺច្រើនជាងនេះ ពីព្រោះ (ក) នៅក្នុងករណីខ្លះ នៅក្នុងសំណុំរឿងមានទាំងសេចក្តីសង្ខេបខ្លីជាភាសាអង់គ្លេសនៃកំណត់ហេតុរបស់ DC-Camផង និងទាំងអត្ថបទពេញលេញផង (កំណត់ហេតុក្រោយនេះ គឺជាការធ្វើប្រតិចារិកដូចគ្នានឹងសម្ភីគ្រប់ម៉ាត់ដែលនៅក្នុងខ្សែអាត់ថតសម្លេង) និង (ខ) ពាក្យបណ្តឹងមួយចំនួនមានច្រើនជាងមួយឯកសារដែលយោងដល់ជនជាប់ចោទ។

[49] *រដ្ឋអាជ្ញា ទល់នឹង Jadranko Prlić និងគូកន,* សំណុំរឿងលេខ IT-04-74-T, សេចក្តីសម្រេចលើការទទួលយកភស្តុតាង អនុលោមតាមវិធាន ៩២*ស្ទួន*(ក) នៃវិធានផ្ទៃក្នុង (Brix-Andersen), ២៣ មករា ២០០៨, កថាខណ្ឌ ១៥។ *សូមអានផងដែរ រដ្ឋអាជ្ញា ទល់នឹង Jovica Stanišić និង Franko Simatović,* សំណុំរឿងលេខ IT-03-69-T, សេចក្តីសម្រេចពាក់ព័ន្ធនឹងសំណើសុំវិធានការការពារ និងការជូនដំណឹងរបស់អយ្យការស្តីពីការអនុវត្តតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៧ ខែតុលា ឆ្នាំ២០១០, ៧ ធ្នូ ២០១០, កថាខណ្ឌ ៧-៩ (ដោយបានបញ្ជាក់ថាអង្គជំនុំជម្រះសាលាដំបូងបានពិនិត្យសម្ភារៈឯកសារឡើងវិញ ហើយបន្ទាប់មក បង្គាប់ឱ្យអយ្យការកោសលុបចេញខ្លះ)។ *រដ្ឋអាជ្ញា ទល់នឹង Vujadin Popović និងគូកន,* សំណុំរឿងលេខ IT-05-88-T, សេចក្តីសម្រេចលើញត្តិ*សម្ងាត់*របស់អយ្យការស្នើសុំឱ្យទទួលយកភស្តុតាងជាលាយលក្ខណ៍អក្សរ ជាជំនួសឱ្យការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ អនុលោមតាមវិធាន ៩២*ស្ទួន*, ១២ កញ្ញា ២០០៦, កថាខណ្ឌ ៣០, ៥៦ (ដូចគ្នា)។

ចូលទៅក្នុងឃ្លាំងផ្ទុកឯកសាររួម ដែលអង្គជំនុំជម្រះ និងមេធាវីការពារក្ដីដែលមានវត្តមាននៅក្នុងសំណុំរឿងលេខ០០២ អាចមានសិទ្ធិចូលទៅពិនិត្យមើលបាន។ ឯកសារទាំងនេះ អាចឱ្យចូលពិនិត្យមើលបាន តាមរយៈគេហទំព័រ Zylab ត្រង់ Link ដាក់ថា ***សំណុំរឿងលេខ ០០២/០១ កំណត់ហេតុដែល កសព បានស្នើសុំឱ្យលុបចេញនូវផ្នែកខ្លះ***។ សហព្រះរាជអាជ្ញាមិនមែនស្នើសុំឱ្យដាក់បញ្ចូលកំណត់ហេតុទាំងនេះ នៅក្នុងសំណុំរឿងនោះទេ នៅក្នុងដំណាក់កាលនេះ ព្រោះថាការណ៍នេះមុខជានឹងនាំឱ្យមានការជាន់គ្នាពីរដងដោយមិនមានការចាំបាច់។ ផ្ទុយទៅវិញ អង្គជំនុំជម្រះអាចស្នើសុំឱ្យដាក់កំណត់ហេតុ "ដែលមានការគូសលប់ចោលផ្នែកខ្លះ"ដែលជាសំណៅអត្ថបទចុងក្រោយ បញ្ចូលទៅក្នុងសំណុំរឿង បន្ទាប់ពីអង្គជំនុំជម្រះបានសម្រេចលើការជំទាស់នានារបស់ក្រុមមេធាវីការពារក្ដី និងលើចម្លើយតបរបស់សហព្រះរាជអាជ្ញារួចហើយ។

៣៣- នៅដំណាក់កាលនេះ ដើម្បីមូលហេតុនៃប្រសិទ្ធភាព ឯកសារដែលត្រូវបានកោសលុបចំនួន២២០ ធ្វើជាភាសាអង់គ្លេស។ ដោយសារភាគីទាំងអស់មានកម្រិតសមត្ថភាពខាងភាសាអង់គ្លេសនោះ គេអាចកំណត់អត្តសញ្ញាណលើខ្លឹមសារពាក់ព័ន្ធ ក្នុងភាសាខ្មែរ និងបារាំង បានឆាប់រហ័ស។ នៅពេលគេធ្វើសេចក្ដីសម្រេចចុងក្រោយស្ដីពីការទទួលយកនោះ សំណៅដែលបានកោសលុបអាចត្រូវបានរៀបចំទាំងបីភាសា។

## ខ. អំពើ និងសកម្មភាពរបស់ជនជាប់ចោទ

៣៤- នៅក្នុងការកំណត់អត្តសញ្ញាណលើអត្ថបទដែលមានផ្ទុកទៅដោយភ័ស្តុតាងស្ដីពីអំពើ និងសកម្មភាពរបស់ជនជាប់ចោទ សហព្រះរាជអាជ្ញាបានធ្វើតាមគោលការណ៍ផ្សេងៗដែលមានចែងនៅខាងក្រោមនេះ ដែលគោលការណ៍ទាំងនេះបានលេចចេញមកពីច្បាប់យុត្តិសាស្ត្រ ដែលអង្គជំនុំជម្រះនេះបានយល់ព្រមទទួលយក។

៣៥- តុលាការ *ពិសេស* នានាធ្លាប់បានសម្រេចថាប្រយោគ "អំពើ និងសកម្មភាពរបស់ជនជាប់ចោទ" ត្រូវតែបានផ្ដល់តាម "អត្ថន័យធម្មតា" របស់វាថាជា "អំពើ និងសកម្មភាពរបស់ជនជាប់ចោទខ្លួនឯងផ្ទាល់

ហើយមិនមែនជា អំពើ និងសកម្មភាពរបស់សហចារីខ្លួន និង/ឬ របស់អ្នកនៅក្រោមបង្គាប់ខ្លួន នោះឡើយ"[50] ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR ធ្លាប់បានសម្រេចថា៖

> "វិធាន ៩២ ស្ទួនមិនរាប់បញ្ចូលនូវ អំពើ និង អាកប្បកិរិយា របស់ជនជាប់ចោទ ដូចដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបង្កើតបានជាការទទួលខុសត្រូវរបស់ខ្លួនចំពោះអំពើ និងសកម្មភាពរបស់ជនដទៃនោះឡើយ ប៉ុន្តែមិនបានផាត់ចេញនូវអំពើ និងសកម្មភាពរបស់ជនដទៃ ដែលជនជាប់ចោទរូបនោះត្រូវបានលើកឡើងចោទប្រកាន់ថាត្រូវទទួលខុសត្រូវ, ឧទាហរណ៍ដូចជា អំពើ និងសកម្មភាពរបស់សហចារី ឬ របស់អ្នកនៅក្រោមបង្គាប់[51]"។

៣៦- ប្រយោគនេះ មានរួមបញ្ចូលនូវភស្តុតាងស្តីពីអំពើ និងសកម្មភាព<u>របស់ជនជាប់ចោទ</u> ដែលមានលំនាំក្នុងការបង្ហាញសក្ខីកម្មថា៖

---

[50] *រដ្ឋអាជ្ញា ទល់នឹង Édouard Karemera និងគូកន,* សេចក្តីសម្រេចលើញត្តិរបស់អយ្យការ ស្នើសុំឱ្យទទួលយកភស្តុតាងស្តីពីការរំលោភសេពសន្ថវៈ និង ការបំពានខាងផ្លូវភេទ អនុលោមតាមវិធាន ៩២*ស្ទួន* នៃវិធានផ្ទៃក្នុង, និងដីកាបង្គាប់ឱ្យកាត់បន្ថយ បញ្ជីឈ្មោះសាក្សី, ១១ ធ្នូ ២០០៦, កថាខណ្ឌ ១០។ *រដ្ឋអាជ្ញា ទល់នឹង Goran Hadžić,* សំណុំរឿងលេខ IT-04-75-T, សេចក្តីសម្រេចលើ ញត្តិចម្រុះរឿងរបស់អយ្យការ (Prosecution Omnibus Motion) ស្នើសុំឱ្យទទួលយកភស្តុតាង អនុលោមតាមវិធាន ៩២*ស្ទួន* និងញត្តិរបស់អយ្យការស្នើសុំឱ្យទទួលយកភស្តុតាងរបស់សាក្សី GH-139 អនុលោមតាមវិធាន ៩២*ស្ទួន*, ២៤ មករា ២០១៣, (បន្ទាប់តទៅនេះ ហៅថា "សេចក្តីសម្រេចលើរឿងក្តី Hadžić" ) កថាខណ្ឌ ១៥។ *រដ្ឋអាជ្ញា ទល់នឹង* Naser Orić, សំណុំរឿងលេខ IT-03-68-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី ស្នើសុំឱ្យទទួលយកភស្តុតាងរបស់សាក្សីមួយរូប ក្នុងទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយ អនុលោមតាម វិធាន ៩២*ស្ទួន*, ៦ ធ្នូ ២០០៥, ទំព័រទី ៣ ("អំពើ និង ការប្រព្រឹត្ត របស់ជនជាប់ចោទ ត្រូវបានផ្តល់អត្ថន័យឱ្យតាមធម្មតា "*ជាអត្ថន័យ ដាច់ខាត - stricto sensu* គឺការធ្វើ និង ចរិយា របស់ជនជាប់ចោទ ហើយមិនពន្លាតទៅដល់ អំពើ និង ការប្រព្រឹត្ត របស់អ្នកនៅក្រោម ឬ របស់សហចារី នោះឡើយ" (ការលើកឡើងផ្ទៃក្នុងត្រូវបានរំលងចោល)។ *រដ្ឋអាជ្ញា ទល់នឹង Naser Orić,* សំណុំរឿងលេខ IT-03-68-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី ស្នើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី Avdo Husejnović អនុលោមតាម វិធាន ៩២*ស្ទួន*, ១៥ កញ្ញា ២០០៥, ទំព័រទី ៣ ("ប្រយោគ "អំពើ និង ការប្រព្រឹត្តរបស់ជនជាប់ចោទ ដូចដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ" តាមវិធាន ៩២*ស្ទួន*(ក) នៃវិធានផ្ទៃក្នុង គឺជាវិញ្ញត្តិត្រង់ៗ និងត្រូវបានផ្តល់អត្ថន័យឱ្យតាមធម្មតា គឺជា ការធ្វើ និង ចរិយា របស់ជនជាប់ចោទ")។ *រដ្ឋអាជ្ញា ទល់នឹង Vidoje Blagojević និង Dragan Jokić,* សំណុំរឿងលេខ IT-02-60-T, សេចក្តីសម្រេចលើកទីមួយលើញត្តិរបស់អយ្យការ ស្នើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងការផ្តល់សក្ខីកម្មជាមុន អនុលោមតាម វិធាន ៩២*ស្ទួន*, ១២ មិថុនា ២០០៣, កថាខណ្ឌ ១៧ ("មិនមានសាក្សីរូបណាមួយដែលបានស្នើតាមវិធាន ៩២*ស្ទួន* បានពោលដោយផ្ទាល់អំពីជនជាប់ចោទណាមួយឡើយ ហើយដូច្នេះ ភស្តុតាងដែលត្រូវទទួលយកតាមរយៈសាក្សីទាំងនេះមិនបានសំដៅដោយត្រង់ៗចំពោះ "អំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ដូចដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នោះឡើយ")។

[51] *រដ្ឋអាជ្ញា ទល់នឹង Édouard Karemera និងគូកន,* សេចក្តីសម្រេចលើញត្តិរបស់អយ្យការ ស្នើសុំឱ្យទទួលយកភស្តុតាងស្តីពីការរំលោភសេពសន្ថវៈ និង ការបំពានខាងផ្លូវភេទ អនុលោមតាមវិធាន ៩២*ស្ទួន* នៃវិធានផ្ទៃក្នុង, និងដីកាបង្គាប់ឱ្យកាត់បន្ថយ បញ្ជីឈ្មោះសាក្សី, ១១ ធ្នូ ២០០៦, កថាខណ្ឌ ១០។ សេចក្តីសម្រេចលើរឿងក្តី Hadžić ត្រង់កថាខណ្ឌ ១៥។

ក. ជនជាប់ចោទបានប្រព្រឹត្ត (គឺថាបានប្រព្រឹត្តដោយផ្ទាល់ខ្លួនឯង) ឧក្រិដ្ឋកម្មណាមួយ ក្នុងចំណោមឧក្រិដ្ឋកម្មទាំងឡាយ។

ខ. ជនជាប់ចោទបានធ្វើផែនការ បានញុះញង់ ឬបានបញ្ជាឲ្យមានឧក្រិដ្ឋកម្ម។

គ. ជនជាប់ចោទ បើមិនដូច្នោះទេ បានជួយ និងបានជំរុញដល់ពួកជនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយដែលមាននៅក្នុងផែនការ នៅក្នុងការរៀបចំ ឬនៅក្នុងកិច្ចប្រតិបត្តិការធ្វើឧក្រិដ្ឋកម្មទាំងនោះ, ឬ

ឃ. ដោយឋិតនៅក្នុងការទទួលខុសត្រូវ ជាថ្នាក់លើ ឬជាការបញ្ជា ជនជាប់ចោទ៖

i. ជាថ្នាក់លើរបស់ជនដែលបានប្រព្រឹត្តិឧក្រិដ្ឋកម្មដោយផ្ទាល់ជាក់ស្តែង។

ii. បានដឹង ឬមានហេតុផលគួរតែបានដឹង ថាឧក្រិដ្ឋកម្មទាំងនោះហៀបតែនឹង ឬត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់របស់ខ្លួន។

iii. ខកខានដោយមិនបានចាត់វិធានការសមស្រប ដើម្បីរារាំងអំពើទាំងនោះ ឬ ដើម្បីដាក់ទណ្ឌកម្មដល់ពួកដែលបានប្រព្រឹត្តនូវអំពើទាំងនោះ[52]។

៣៧- កាលណា JCE ត្រូវបានចោទប្រកាន់ ប្រយោគដែលគ្របដណ្តប់លើភ័ស្តុតាងនៃអំពើ ឬសកម្មភាពណាមួយរបស់ជនជាប់ចោទ ដែលអយ្យការបានពឹងផ្អែក ដើម្បីបង្កើតឲ្យបានថាជនជាប់ចោទរូបនោះ ឬមួយ៖ (ក) បានចូលរួមចំណែកនៅក្នុង JCE ឬមួយក៏ (ខ) បានចូលរួមប្រព្រឹត្តជាមួយនឹងជនដែលពិតជាបានប្រព្រឹត្តជាក់ស្តែងនូវឧក្រិដ្ឋកម្មមានចេតនាគ្រប់គ្រាន់ ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ[53]។

---

[52] សេចក្តីសម្រេចលើរឿងក្តី Hadžić ត្រង់កថាខណ្ឌ ១៥។ *រដ្ឋអាជ្ញា ទល់នឹង Naser Orić,* សំណុំរឿងលេខ IT-03-68-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី ស្នើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី Avdo Husejnović អនុលោមតាមវិធាន ៩២*ស្ទួន*, ១៥ កញ្ញា ២០០៥, ទំព័រទី ៣។ *រដ្ឋអាជ្ញា ទល់នឹង Vidoje Blagojević និង Dragan Jokić,* សំណុំរឿងលេខ IT-02-60-T, សេចក្តីសម្រេចលើកទីមួយលើញត្តិរបស់អយ្យការ ស្នើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងការផ្តល់សក្ខីកម្មជាមុន អនុលោមតាមវិធាន ៩២*ស្ទួន*, ១២ មិថុនា ២០០៣, កថាខណ្ឌ ៩។

[53] *រដ្ឋអាជ្ញា ទល់នឹង Édouard Karemera និងគូកន,* សេចក្តីសម្រេចលើញត្តិរបស់អយ្យការ ស្នើសុំឲ្យទទួលយកភស្តុតាងស្តីពីការរំលោភសេពសន្ថវៈ និង ការបំពានខាងផ្លូវភេទ អនុលោមតាមវិធាន ៩២*ស្ទួន* នៃវិធានផ្ទៃក្នុង, និងដីកាបង្គាប់ឲ្យកាត់បន្ថយ បញ្ជីឈ្មោះសាក្សី, ១១ ធ្នូ ២០០៦, កថាខណ្ឌ ១៣។ សេចក្តីសម្រេចលើរឿងក្តី Hadžić ត្រង់កថាខណ្ឌ ១៥-១៦។ *រដ្ឋអាជ្ញា ទល់នឹង Vidoje Blagojević និង Dragan Jokić,* សំណុំរឿងលេខ IT-02-60-T, សេចក្តីសម្រេចលើកទីមួយលើញត្តិរបស់អយ្យការ ស្នើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងការផ្តល់សក្ខីកម្មជាមុន អនុលោមតាមវិធាន ៩២*ស្ទួន*, ១២ មិថុនា ២០០៣, កថាខណ្ឌ ១១។

៣៨- ភ័ស្តុតាងនេះត្រូវធ្វើឲ្យខុសគ្នាពីភ័ស្តុតាងស្តីពីអំពើ និងសកម្មភាពរបស់ជនដទៃដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលជនជាប់ចោទរូបនោះត្រូវបានគេចោទប្រកាន់ថាត្រូវមានការទទួលខុសត្រូវ (ដូចជា អ្នកនៅក្រោមបង្គាប់កៀកនឹងខ្លួនផ្ទាល់។ ភ័ស្តុតាងបែបដូច្នេះ <u>គឺមិន</u>អាចទទួលយកបានឡើយ ដោយហេតុមកពីវិធាន ៩២*ស្ទួន*។ ផ្ទុយទៅវិញ នៅតុលាការ*ពិសេសនានា* ការទទួលយកភ័ស្តុតាងបែបនេះ តម្រូវឲ្យមានការពិចារណាមួយថា តើអង្គជំនុំជម្រះត្រូវអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការកោះហៅសាក្សីទាំងឡាយឲ្យមកផ្តល់សក្ខីកម្មដោយផ្ទាល់ ដែរ ឬមួយយ៉ាងណា[54]។

## គ. ការជ្រើសរើសសាក្សីដែលត្រូវកោះហៅឲ្យមកផ្តល់សក្ខីកម្ម

៣៩- ដំណើរការនៃការពិនិត្យឡើងវិញខាងលើនេះ និងការវិភាគរបស់សហព្រះរាជអាជ្ញាលើស្ថានភាពនៃសំណុំរឿង បានបង្ហាញថា គេត្រូវកោះហៅសាក្សីបន្ថែមទៀត ដោយសារតែតម្លៃនៃភ័ស្តុតាង ស្តីពីអំពើ និងសកម្មភាព ដែលសាក្សីទាំងនោះអាចនឹងផ្តល់បាន (ឬដោយសារតែតម្លៃនៃភ័ស្តុតាងទាំងនោះចំពោះទិដ្ឋភាពស្នូលនៃសំណុំរឿង) និងដើម្បីធ្វើការធានាថា ជនជាប់ចោទមានឱកាសក្នុងការសួរដេញដោលពីភ័ស្តុតាងនោះ។ សហព្រះរាជអាជ្ញាបានកំណត់អត្តសញ្ញាណសាក្សីទាំងនេះ នៅក្នុងញត្តិស្នើសុំនាពេលថ្មីៗនេះ ដែលមាននិយាយពីផែនការដែលបានស្នើឡើងសម្រាប់បញ្ចប់សវនាការ[55]។ កំណត់ហេតុស្តាប់ចម្លើយសាក្សី និងពាក្យបណ្តឹង (ដកចេញកំណត់ហេតុ និងពាក្យបណ្តឹងដែលជាប់ទាក់ទងនឹង ស-២១) មានចុះក្នុងបញ្ជីនៃផ្នែក ខ នៃឧបសម្ព័ន្ធទី១២ និង១៣ ដែលបានកែសម្រួលឡើងវិញ។ កំណត់ហេតុ និងពាក្យបណ្តឹងទាំងនេះ (នៅក្នុងឧបសម្ព័ន្ធទី១២) គឺកំណត់ហេតុស្តាប់ចម្លើយសាក្សី២ ដែលមេធាវីការពារក្តីបានស្នើសុំ។

៤០- ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយដទៃទៀតដែលមានភ័ស្តុតាងស្តីពីអំពើ និងសកម្មភាពរបស់ជនជាប់ចោទ (ផ្នែក គ នៃឧបសម្ព័ន្ធ ១២ ដែលបានកែសម្រួលឡើងវិញ គឺបើកចំហសម្រាប់ឲ្យអង្គជំនុំ

[54] សេចក្តីសម្រេចលើរឿងក្តី Hadžić ត្រង់កថាខណ្ឌ ១៥, ២៩។ *រដ្ឋអាជ្ញា ទល់នឹង Vidoje Blagojević និង Dragan Jokić*, សំណុំរឿងលេខ IT-02-60-T, សេចក្តីសម្រេចលើកទីមួយលើញត្តិរបស់អយ្យការ ស្នើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងការផ្តល់សក្ខីកម្មជាមុន អនុលោមតាមវិធាន ៩២*ស្ទួន*, ១២ មិថុនា ២០០៣, កថាខណ្ឌ ១២។

[55] **E273** កាលវិភាគសម្រាប់សវនាការស្នើឡើងដោយសហព្រះរាជអាជ្ញា (ជាមួយឧបសម្ព័ន្ធ ក សម្ងាត់), ២៧ មីនា ២០១៣ - សូមអានឧបសម្ព័ន្ធ ក នៅក្នុង E273.1 សម្រាប់បញ្ជីឈ្មោះសាក្សី។

ជម្រះអនុម័តលើកិច្ចដំណើរការនីតិវិធីដែលបានបំពេញខ្លី ដែលខ្លួនបានអនុម័តទាក់ទងទៅនឹងប្រតិចារឹក (ដូចជាវិធាន ៩២*ស្ទួន* នៃតុលាការ ICTY) ដែលគេអាចកោះហៅសាក្សីឱ្យមកផ្តល់សក្ខីកម្មសំខាន់ៗ សង្ខេបខ្លី (ដើម្បីបញ្ជាក់ពីការពិតនៃចម្លើយរបស់ខ្លួន ដែលមានជាប់ទាក់ទងទៅនឹងជនជាប់ចោទ) ហើយបន្ទាប់មកត្រូវបានសួរដេញដោលដោយអង្គជំនុំជម្រះ និងមេធាវីការពារក្តី។ ការណ៍នេះនឹងអនុញ្ញាតឱ្យទទួលយកនូវភ័ស្តុតាងជាភវនីយភាពមួយចំនួន ដែលថាបើមិនដូច្នោះទេ ភ័ស្តុតាងទាំងនោះនឹងត្រូវបានដកចេញ។

៤១- ដូចដែលបានថ្លែងនៅក្នុងកថាខណ្ឌទី៣៤ ដល់៣៨ ខាងលើ វិធានបដិសេធភ័ស្តុតាងមានអនុវត្តនៅក្នុងកម្រិតអន្តរជាតិ ទាក់ទងតែភ័ស្តុតាងទាំងឡាយណាដែលនិយាយពីអំពើ និងសកម្មភាពរបស់ជនជាប់ចោទខ្លួនឯងប៉ុណ្ណោះ។ តុលាការមានភាពច្បាស់លាស់ណាស់ថា កាលណាភ័ស្តុតាងនិយាយពីអំពើ និងសកម្មភាពរបស់អ្នកនៅក្រោមបង្គាប់របស់ជនជាប់ចោទរូបនោះ គឺវាត្រូវឋិតនៅក្រោមឆន្ទានុសិទ្ធិរបស់តុលាការក្នុងការទទួលយកភ័ស្តុតាងនោះ ដោយពុំមានតម្រូវឱ្យសាក្សីពាក់ព័ន្ធមកផ្តល់សក្ខីកម្មឡើយ។ នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិនេះ អង្គជំនុំជម្រះសាលាដំបូងនានាធ្លាប់បានធ្វើការពិចារណាថា តើភ័ស្តុតាងនេះជា “ភ័ស្តុតាងស្នូលចំពោះអយ្យការ” ដែរ ឬមួយយ៉ាងណា ហើយថាតើអ្នកក្រោមបង្គាប់ “នៅកៀកផ្ទាល់នឹងជនជាប់ចោទ” ដែរ ឬមួយយ៉ាងណា ក្នុងការដែលអនុញ្ញាតឱ្យគេទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយនោះ ដោយមិនមានការសួរដេញដោល[56]។

[56] *រដ្ឋអាជ្ញា ទល់នឹង Goran Hadžić,* សំណុំរឿងលេខ IT-04-75-T, សេចក្តីសម្រេចលើញត្តិចម្រុះរឿងរបស់អយ្យការ (Prosecution Omnibus Motion) ស្នើសុំឱ្យទទួលយកភស្តុតាង អនុលោមតាមវិធាន ៩២*ស្ទួន* និងញត្តិរបស់អយ្យការស្នើសុំឱ្យទទួលយកភស្តុតាងរបស់សាក្សី GH-139 អនុលោមតាមវិធាន ៩២*ស្ទួន,* ២៤ មករា ២០១៣, ត្រង់កថាខណ្ឌ ១៨។ *រដ្ឋអាជ្ញា ទល់នឹង Vidoje Blagojević និង Dragan Jokić,* សំណុំរឿងលេខ IT-02-60-T, សេចក្តីសម្រេចលើកទីមួយលើញត្តិរបស់អយ្យការ ស្នើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងការផ្តល់សក្ខីកម្មជាមុន អនុលោមតាមវិធាន ៩២*ស្ទួន,* ១២ មិថុនា ២០០៣, ត្រង់កថាខណ្ឌ ១២។ *រដ្ឋអាជ្ញា ទល់នឹង Naser Orić,* សំណុំរឿងលេខ IT-03-68-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី ស្នើសុំឱ្យទទួលយកភស្តុតាងរបស់សាក្សីមួយរូប ក្នុងទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយ អនុលោមតាមវិធាន ៩២*ស្ទួន,* ៦ ធ្នូ ២០០៥, ទំព័រទី ៣។ *រដ្ឋអាជ្ញា ទល់នឹង Édouard Karemera និងគូកន,* សំណុំរឿងលេខ ICTR-98-44-T, សេចក្តីសម្រេចលើញត្តិរបស់អយ្យការស្នើសុំឱ្យទទួលយកភស្តុតាងស្តីពីការរំលោភសេពសន្ថវៈ និង ការបំពានខាងផ្លូវភេទ អនុលោមតាមវិធាន ៩២*ស្ទួន* នៃវិធានផ្ទៃក្នុង, និងដីកាបង្គាប់ឱ្យកាត់បន្ថយបញ្ជីឈ្មោះ សាក្សី, ១១ ធ្នូ ២០០៦, កថាខណ្ឌ ១២។ សូមអានផងដែរ វិធាន ៩២(គ) នៃវិធានផ្ទៃក្នុង។

## V. បញ្ហាស្តីពីការបញ្ជាក់របស់សាក្សី

៤២- សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងមិនបានតម្រូវឱ្យមានការបញ្ជាក់របស់សាក្សី ដូចមានចែងក្នុងវិធានរបស់តុលាការ ICTY តាមវិធាន ៩២*ស្ទួន* (ខ) ឡើយ[57]។ សហព្រះរាជអាជ្ញាយល់ស្របទៅនឹងវិធីសាស្ត្រនេះ ដោយគោរពថាវិធាននេះផ្តល់នូវមូលហេតុយ៉ាងត្រឹមត្រូវដល់ខ្លឹមសារនៃវិធាន៩២*ស្ទួន* ដែលបានលើកឡើងនៅក្នុងរចនាសម្ព័ន្ធ និងកាលៈទេសៈរបស់ អ.វ.ត.ក។ ជាឧទាហរណ៍ បានយកមកពិចារណាយ៉ាងហ្មត់ចត់អំពីអង្គហេតុពិតដែលថា ភាគច្រើននៃកំណត់ស្តាប់ចម្លើយ និងពាក្យបណ្តឹងនៅក្នុងឧបសម្ព័ន្ធ ១២ និង ១៣ ត្រូវបានគេធ្វើការប្រមូល មិនមែនដោយភាគីនានា ឬដោយទីភ្នាក់ងារអនុវត្តច្បាប់ក្នុងប្រទេសនោះឡើយ (មិនដូចជារឿងក្តី នៅតុលាការ *ពិសេស* នោះទេ) ប៉ុន្តែផ្ទុយទៅវិញ គឺធ្វើឡើងដោយបុគ្គលិករបស់អង្គជំនុំជម្រះ និង របស់អង្គការខាងក្រៅដែលស្វែងរកការបង្កើតកំណត់ត្រាប្រវត្តិសាស្ត្រ។ លក្ខខណ្ឌតម្រូវនៃការបញ្ជាក់ក៏មានច្រើនហួសពីសេចក្តីត្រូវការ ផងដែរ កាលណាកំណត់ហេតុស្តាប់ចម្លើយមាន *សញ្ញាចង្អុល*ពីភាពទុកចិត្តបានដទៃទៀតជាច្រើន- ជាឧទាហរណ៍ កំណត់ហេតុស្តាប់ចម្លើយរបស់ DC Cam គឺជាប្រតិចារឹកដែលត្រង់ៗតាមពាក្យគ្មានល្អៀង ចេញពីការថតសម្លេងបទសម្ភាសន៍ និងមិនអាចមានការលើកឡើងដែលគួរឱ្យជឿបានណាមួយស្តីពីឥទ្ធិពលមិនសមស្របទៅលើសាក្សីនោះឡើយ (កំណត់ហេតុស្តាប់ចម្លើយមួយចំនួនក៏មានផ្ទុកទៅដោយភ័ស្តុតាងដោះបន្ទុកផងដែរ)។ អភិក្រមរបស់អង្គជំនុំជម្រះបានបង្ហាញផងដែរនូវការពិចារណាអំពីអង្គហេតុពិតដែលថា តាមរយៈគុណធម៌នៃការដាក់ចូលក្នុងសំណុំរឿង គ្រប់កំណត់ហេតុស្តាប់ចម្លើយទាំងអស់ ធ្លាប់ត្រូវបានឆ្លងកាត់ការពិនិត្យឡើងវិញ តាមផ្លូវតុលាការ ដែលធ្វើឡើងដោយ ក.ស.ច.ស។

## VI. ស្ថានភាពនៃការបកប្រែភាសា

៤៣- ភាគច្រើននៃឯកសារដែលមានចុះជាបញ្ជីនៅក្នុងឧបសម្ព័ន្ធ ១២ និង ១៣ ដែលបានកែសម្រួលឡើងវិញ គឺអាចរកបានជាភាសាផ្លូវការរបស់អង្គជំនុំជម្រះ៖ គ្រប់ឯកសារទាំងអស់ លើកលែងតែឯកសារ ២(ពីរ) អាចរកបានជាភាសាខ្មែរ, គ្រប់ឯកសារទាំងអស់អាចរកបានជាភាសាអង់គ្លេស ហើយឯកសារទាំងអស់ ប៉ុន្តែឯកសារចំនួន៣៧ មានជាភាសាបារាំង។ ករណីផ្សេងទៀត ការបកប្រែជាផ្នែក

[57] **E96/7** សេចក្តីសម្រេចលើកកំណត់ហេតុស្តាប់ចម្លើយសាក្សី, ២០ មិថុនា ២០១២។

ឬជាសង្ខេប មាននៅពេលបច្ចុប្បន្ននេះ នៅពេលការបកប្រែពេញលេញកំពុងដំណើរការ។ ជាងពីរឆ្នាំមកនេះ សហព្រះរាជអាជ្ញាបានធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងអង្គភាពបកប្រែភាសា (ITU) ដើម្បីធានាថា គេបានធ្វើការបកប្រែគ្រប់ឯកសារទាំងអស់។ ជាអកុសល ITU បានពន្យារកាលបរិច្ឆេទកំណត់ក្នុងការបកប្រែជាច្រើនដង ដោយមកពីធនធានរបស់ខ្លួននៅមានកម្រិត និងអាទិភាពដែលជែងគ្នា។

៤៤- នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាបានដាក់សំណើមួយ សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្កើតនីតិវិធីមួយសម្រាប់ទទួលយកឯកសារទាំងឡាយ ដែលមិនទាន់បានបកប្រែជាភាសាផ្លូវការទាំងបី[58]។ ដូចដែលអង្គបុរេជំនុំជម្រះបានអះអាងបញ្ជាក់ដែរ សហព្រះរាជអាជ្ញារំលឹកថា វាមិនមានលក្ខខណ្ឌតម្រូវណាមួយ នៅក្នុងច្បាប់ជាតិក្តី ឬច្បាប់អន្តរជាតិក្តី ឲ្យមានការបកប្រែភស្តុតាងទាំងអស់ឲ្យទៅជាភាសាផ្លូវការទាំងបីរបស់អង្គជំនុំជម្រះនោះទេ។ ដោយសារមានភាគរយច្រើននៃការបកប្រែឯកសារនៅក្នុងឧបសម្ព័ន្ធ ១២ និង ១៣ ដែលអាចមានស្រាប់រួចមកហើយៗ មានឯកសារមួយចំនួនតូចនៅរង់ចាំការបកប្រែដែលគេនឹងត្រូវបញ្ចប់ក្នុងពេលដ៏ខ្លី សហព្រះរាជអាជ្ញាសូមឱ្យអង្គជំនុំជម្រះ ទទួលយកគ្រប់ឯកសារទាំងអស់ក្នុងពេលឥឡូវនេះ។ នៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះ មិនអាចមានការបញ្ជាក់ណាមួយដែលគួរឱ្យទុកចិត្តបានអំពីភាពគ្មានយុត្តិធម៌ចំពោះជនជាប់ចោទឡើយ។

## VII. សេចក្តីសន្និដ្ឋាន និងសំណើសុំ

៤៥- សហព្រះរាជអាជ្ញា សូមស្នើដល់ អង្គជំនុំជម្រះសាលាដំបូង ដោយគោរពថា សូមឱ្យ៖

ក. <u>កោះហៅ</u>សាក្សីទាំងឡាយដែលនៅសល់ ដែលកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគាត់មានចុះបញ្ជីនៅក្នុងផ្នែក ខ នៃឧបសម្ព័ន្ធទី១២ និងទី១៣ ដែលបានកែសម្រួល ដើម្បីធានាថាភស្តុតាងរបស់ពួកគាត់ជាពិសេសពាក់ព័ន្ធនឹងអំពើ និងសកម្មភាពរបស់ជនជាប់ចោទអាចត្រូវបានពិចារណាដោយអង្គជំនុំជម្រះ នៅក្នុងការបញ្ជាក់ការពិត។

---

[58] **E223/2/6** សំណើរបស់សហព្រះរាជអាជ្ញាសុំបង្កើតនីតិវិធីពាក់ព័ន្ធនឹងការទទួលយកឯកសារដែលមិនបានបកប្រែគ្រប់ភាសាទាំងអស់របស់ អ.វ.ត.ក, ២៨ កុម្ភៈ ២០១៣។

ខ. <u>ពិចារណា</u>ថាតើគេត្រូវស្តាប់ចម្លើយសាក្សីបន្ថែម ដែលសក្ខីកម្មនោះមានភ័ស្តុតាងអំពីអំពើ និងសកម្មភាពរបស់ជនជាប់ចោទ (នៅក្នុងផ្នែក គ នៃឧបសម្ព័ន្ធ ១២ និង ១៣ ដែលបាន កែសម្រួលឡើងវិញ គួរត្រូវបានស្តាប់ តាមវិធីកិច្ចដំណើរការនីតិវិធីសង្ខេបខ្លី យ៉ាងណា (ដូចមានចែងក្នុងវិធាន៩២ស្ទួនពីររបស់តុលាការ ICTY)។

គ. <u>ទទួលយក</u>កំណត់ហេតុស្តាប់ចម្លើយសាក្សី និងពាក្យបណ្តឹងទាំងឡាយ ក្នុងបញ្ជីក្នុង ឧបសម្ព័ន្ធទី១២ និង១៣ ដូចខាងក្រោម៖

**ទាំងស្រុង៖**

i. (ប្រសិនបើមិនទាន់បានទទួលយក) ក្នុងករណីដែលម្ចាស់កំណត់ហេតុនឹងបានផ្តល់ សក្ខីកម្មក្នុងពេលសវនាការ (ផ្នែក ក និង ខ ឧបសម្ព័ន្ធដែលបានកែសម្រួល ឡើងវិញ)

ii. ក្នុងករណី ដែលម្ចាស់បានទទួលមរណភាព ឬមិនមានលទ្ធភាពមកបាន (ផ្នែក ឃ នៃឧបសម្ព័ន្ធ ១២ ដែលបានកែសម្រួលឡើងវិញ) និង

iii. ក្នុងករណីដែលម្ចាស់នឹងមិនបានផ្តល់សក្ខីកម្មនៅពេលសវនាការ <u>និង</u> ក្នុងករណី ដែលកំណត់ហេតុស្តាប់ចម្លើយនោះមិនមានភ័ស្តុតាងអំពីអំពើ និងសកម្មភាព របស់ជនជាប់ចោទ (ក្នុងផ្នែក គ នៃឧបសម្ព័ន្ធ១២ និង ១៣ ដែលបានកែសម្រួល ឡើងវិញ)។

<u>ដកចេញផ្នែកកំណត់</u>

iv. ក្នុងករណីដែលម្ចាស់នឹងមិនផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះទេ <u>ហើយ</u> ក្នុងករណីដែលកំណត់ហេតុស្តាប់ចម្លើយ/ពាក្យបណ្តឹងមានភ័ស្តុតាងអំពីអំពើ <u>និង</u>

សកម្មភាពរបស់ជនជាប់ចោទ (ផ្នែក គ នៃឧបសម្ព័ន្ធទី១២ និង១៣ ដែលបានកែសម្រួលឡើងវិញ)។

ឃ. ទទួលយកទាំងស្រុងឯកសារដែលនៅសេសសល់ ក្នុងឧបសម្ព័ន្ធទី១១៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៣ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Andrew CAYLEY** សហព្រះរាជអាជ្ញា | | |